# ពិភពលោកនៃ អែសរ៉ា នេហេមា និងនាងអេសធើរ



លោកបណ្ឌិត វ៉ាយ យ៉ុង ជុន

## មេរៀនទី១

## ការស្វាបស្វង់មតិ ហោរាអែសរ៉ា ហោរានេហេមា និងនាងអេធើរ

**ក. ការស្វង់មតិ៖** ហោរាអែសរ៉ា និង ហោរានេហេមា គឺជាអ្នកដែលបានសរសេរព្រឹត្តិការណ៍ចុងក្រោយនៅក្នុងកណ្ឌគម្ពីរសញ្ញាចាស់។ ព្រឹត្តការណ៍នៃថ្ងៃចុងក្រោយនោះបានកំណត់សម្រេចថាហោរាអែសរ៉ាគឺមនុស្សចុងក្រោយនៅក្នុងគម្ពីរសញ្ញាចាស់ហើយជាអ្នកដែលពណ៌នាពីព្រះអង្គដែលត្រូវយាងមកសម្រេចបំពេញនូវកណ្ឌគម្ពីរទាំងមូល។ នៅក្នុងកណ្ឌគម្ពីរអែសរ៉ានិងនេហេមាមានមួយភាគដែរ។

**ខ. វត្ថុបំណងនៃសាសនវិទ្យា**

ដោយយោងទៅតាម Eskenazi មានវត្ថុបំណង ៣ចំនុចដូចខាងក្រោម៖

១. យើងឃើញថាមាន ការផ្លាស់ប្រែមេដឹកនាំ នៅក្នុងពួកជំនុំ។

២. ភាពបរិសុទ្ធ និងមិនត្រូវបានកំណត់ នៅកន្លែងពិសេសណាមួយទៀតឡើយ។

៣. យើងឃើញថា ពាក្យអចាមរ៉ាមដែលនិយាយតៗគ្នាត្រូវបានសរសេរទុកជាឯកសារសំខាន់វិញ។

**គ. ទំនាក់ទំទងទៅនិងព្រះគម្ពីរសញ្ញាថ្មី**

១. ព្រះយេស៊ូវគឺជាម្នាក់ ដែលបានបំផ្លាញរនាំងបាំង រវាងព្រះហើយនិងមនុស្ស

២. ព្រះយេស៊ូវគឺជាម្នាក់ បានញែករាំងនន នៅទីបរិសុទ្ធបំផុតដែលបិតនៅ

ចន្លោះ សាសន៍យូដានិងសាសន៍ដទៃ(អេភេសូ២:១៤-១៨)

ឃ.ការបែងចែកមាតិកា

**១. គោលបំណងសំខាន់: សេចក្តីបង្គាប់របស់ស្តេចស៊ីរូសស្អាងព្រះវិហានៃព្រះយេហូវ៉ា(អែសរ៉ា១:១-៤)**

**២. ពួកជំនុំស្អាងព្រះវិហានៃព្រះយេហូវ៉ា(អែសរ៉ា១:៥-នេហេមា៧:៧២)**

**ក.** សេចក្តីផ្តើម: ប្រជាជនបានរៀបចំធ្វើដំណើរទៅកាន់ស្រុកកំណើតវិញ(អែសរ៉ា១:៥-៦

**ខ.**ការប្រឆាំងនឹង ការសាងសង់អាសនានិងព្រះវិហារឡើងវិញ (១:៧-៦:២២)។

**គ.** ហោរាអែសរ៉ាបានវិលមក ទឹកដីដែលពោពេញដោយបញ្ហាមានប្តីឬប្រពន្ធច្រើន និងបានប្រមូលផ្តុំពួកជំនុំ (អែសរ៉ា ៧:១-១០:៤៤)។

**ឃ.** ហោរានេហេមា បានមកកាន់ទឹកដីវិញ ហើយបានសាងសង់កំផែងបរិសុទ្ធ ក្នុងពេលមានការប្រឆាំងគ្នា (នេហេមា ១:១-៧:៥)។

**ង.** សរុបសេចក្តី: ជំរឿនប្រជាជនយូដាដែលវិលត្រឡប់មកស្រុកវិញ (នេហេមា៧:៦-៧:៧២)។

**៣. ការឈានដល់ទៅគោលដៅ: ពិធីសម្រាប់កិច្ចបង្ហើយនៃការស្អាងព្រះវិហារនៃព្រះយេហូវ៉ាទៅតាមក្រិត្យវិន័យលោកម៉ូសេ (៧:៧៣-១៣:៣១)។**

# មេរៀនទី២

# ពួកជំនុំឡើងទៅស្អាងព្រះវិហារនៃព្រះយេហូវ៉ា

# (អែសរ៉ា ១:៥-នេហេមា ៧:៧២)។

**ក. សេចក្តីផ្តើម:** ប្រជាជនបានរៀបចំធ្វើដំណើរទៅកាន់ស្រុកកំណើតវិញ(អែសរ៉ា១:៥-៦

**ខ.**ប្រជាជនបានស្អាងអាសនានិងព្រះវិហារនៅក្នុងពេលមានការប្រឆាំងគ្នា(១:៧-៦:២២)។

**១. អែសរ៉ា**

**១. ភារកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ (អែសរ៉ា ១:១-១១)**

អែសរ៉ាគឺជាហោរារបស់ព្រះនឹងជាអ្នកប្រាជ្ញខាងច្បាប់ ដែលព្រះបានរើសតាំងឡើង បន្ទាប់ពីអ៊ីស្រាអែលបានរួចផុតពីការនិរទេស ចេញពីក្រុងបាប៊ីលូនវិលត្រឡប់មកកាន់ទឹកដីរបស់ខ្លួន។ តើអ្វីខ្លះ ដែលជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ?

ទី១ យើងឃើញពី កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលបានចាប់ផ្តើមជាមួយព្រះអង្គផ្ទាល់។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការអស្ចារ្យ ដូចជានៅក្នុងការទស្សទាយ របស់ហោរាយេរេមា នៅពេលដែលសមស្រប។ ព្រះបាន

តែងតាំង កូរេជាស្តេចហើយបានបញ្ជាឱ្យ ត្រឡប់ទៅក្រុងយេរូសាឡិមវិញ ហើយបានសង់ព្រះវិហារនៅទីនោះ។ រាល់កិច្ចការរបស់ព្រះត្រូវបានចាប់ផ្តើម ដោយព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណ ដែលទ្រង់ចាប់តាំងធ្វើការល្អ ក្នុងអ្នករាល់គ្នា នោះទ្រង់នឹងធ្វើឲកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ(ភីលីព ១:៦)។ ទី២ ព្រះទ្រង់នឹងលើកតាំង រាស្ត្រនៃព្រះវិញ្ញាណរបស់ទ្រង់ឡើង។ទោះបីជាព្រះវិញ្ញាណ ធ្វើការនៅក្នុងអ្នករាល់គ្នាក៏ដោយ ក៏ទ្រង់មិនព្រងើយកន្តើយនឹងសកម្មភាពរបស់មនុស្ស ដោយគ្មានផែនការណ៍ដែរ។ ព្រះវិញ្ញាណបរិសុទ្ធ ធ្វើការដូចដែលហោរាអែសរ៉ា ធ្វើការតាម  រយៈពួកជំនុំនៃព្រះវិញ្ញាណបរិសុទ្ធ និងគឺជាពួកជំនុំដែលត្រូវបានកោតសរសើរដោយព្រះ។ ទី3 មានតែព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដែលអាចបំពេញ រូបភាពរបស់ព្រះគ្រីស្ទ  ថាគឺជាព្រះវិហារដ៏ពិត។ សម្រាប់ការងារនេះ យើងគួរតែ ទទួលយកភាពពេញលេញនៃព្រះវិញ្ញាណបរិសុទ្ធ។ ខ្លួនអ្នករាល់គ្នា ជាព្រះវិហារនៃព្រះ ហើយថាព្រះវិញ្ញាណនៃព្រះទ្រង់សណ្ឋិតក្នុងអ្នករាល់គ្នា (១កូរិនថូស ៣:១៦)។

## ២. ការរៀបចំកម្មករ (អែសរ៉ា ២:១-៥៤)

ដើម្បីសម្រេចបេសកកម្មសម្រាប់សាងសង់ព្រះវិហារ ព្រះបានរៀបចំរបៀបធ្វើទាំងអស់។ តើបទគម្ពីរបានបង្ហាញអ្វីខ្លះ? ទី១ ព្រះបានរៀបចំកូនចៅជំនាន់ក្រោយ នៃជនដែលត្រូវនិរទេសជំនាន់ដំបូង (១-២)។ ក្នុងនោះមានមេដឹកនាំដែលពេញដោយព្រះវិញ្ញាណដូចជា សូរ៉ូបាបិល នេហេមា អែសរ៉ា។ល។ ដែលជាមនុស្សជំរុញដោយព្រះវិញ្ញាណបរិសុទ្ធ។ ជាអ្នកដែលស្រលាញ់ព្រះបន្ទូល នឹងជឿលើព្រះបន្ទូលដោយផ្ទាល់ គឺពិតជាមានតម្លៃ

ណាស់។ ទី២ ព្រះបានរៀបចំពួកចម្រៀង(៤១)។ ពួកគេបានថ្វាយបង្គំព្រះនេះជាការសំខាន់សម្រាប់ប្រជារាស្ត្ររបស់ព្រះ។ ដូចជាអ័ប្រាហាំបានថ្វាយពពែឈ្មោលមួយ ថ្វាយព្រះយេហូវ៉ាជំនួសឲអ៊ីសាក ពួកគេគួរតែក្លាយជាអ្នកដែលរៀបចំការសរសើរតម្កើង នៅក្នុងសេចក្តីពិតនិងព្រះវិញ្ញាណ។ ទី៣ ពួកគេបានរៀបចំពួកអ្នកឆ្មាំទ្វារ (៤២) មានន័យថា ជាមនុស្សដែលថែរក្សាព្រះវិហារនឹងគ្រប់គ្រងនៅទីនោះ។ ដូចជាព្រះបានរៀបចំពួកអ្នកគង្វាល ដូចព្រះយេស៊ូវបានយាងមក ក្នុងលោកីយជាដំបូង។ព្រះយេហូវ៉ា ធ្វើការតាមរយៈព្រះយេស៊ូវ ដែលបានរៀបចំសម្រាប់ព្រះយេស៊ូវ។ព្រះបានរៀបចំមនុស្សសម្រាប់សាងសង់ព្រះវិហារ។

## ៣. ព្រះប្រើប្រាស់របស់បរិសុទ្ធ (អែសរ៉ា ២:៥៥-៧០)

ព្រះទ្រង់ប្រើរាស្ត្របរិសុទ្ធ តើបទគម្ពីរ បានបង្ហាញអ្វីខ្លះដល់យើង? ទី១ បារស៊ីឡាយ បានហាមគេថា មិនត្រូវបរិភោគពីរបស់បរិសុទ្ធបំផុតឡើយ ដរាបដល់គ្រា មានសង្ឃម្នាក់តាំងឡើង ដែលមានយូរីម នឹងធូមីម(អែសរ៉ា ២:៦៣)។ ព្រះបានប្រើមនុស្សស្មោះត្រង់។ ទី២ ព្រះបានរៀបចំ អ្នកថែរក្សាតង្វាយបរិសុទ្ធ ដែលទុកសម្រាប់សាងសង់ព្រះវិហារឡើងវិញ។ ព្រះទទួលយកតង្វាយបរិសុទ្ធ សម្រាប់ស្អាងព្រះវិហារ។ដូច្នេះហើយ បានជាយើងសង្កត់ធ្ងន់លើភាពបរិសុទ្ធ ហើយយើងត្រូវតែ ពិនិត្យមើលភាពបរិសុទ្ធខ្លួនឯងជានិច្ច។ ព្រះទ្រង់ចង់បានដួងចិត្តដែលថ្វាយស្ម័គ្រពីចិត្ត នឹងមានពេញដោយ សេចក្តីអំណរ។ យើងរាល់គ្នា បានបរិសុទ្ធដោយសារឈាមវិសេសព្រះយេស៊ូវ។

## ៤. ការស្អាងអាសនា (អែសរ៉ា ៣:១-១៣)

ដូចដែលស្ដេចសាឡូម៉ូន បានរើសកម្មករចំនួន១សែននាក់ ដើម្បីសាងសង់ព្រះវិហារ។ ជាដំបូង គេនាំគ្នាស្អាងអាសនានៃព្រះ ដើម្បីថ្វាយតង្វាយដុត។ តើមានបញ្ញត្តអ្វីខ្លះ? ទី១ គឺត្រូវធ្វើតាមព្រះបន្ទូលរបស់ព្រះ តាមដែលបានកត់ទុកក្នុងក្រឹត្យវិន័យ របស់លោកម៉ូសេ ជាអ្នកសំណប់របស់ព្រះ។ ព្រះបន្ទូលរបស់ព្រះគឺជាអាទិភាពចម្បង គឺជាគ្រឹះនៃព្រះវិហារ (អេភេសូ២:២០)។ ទី២ អាសនា ត្រូវបានស្ដារឡើងវិញ ព្រោះការសាងសង់ផ្អែកលើព្រះបន្ទូលរបស់ព្រះ ដោយការថ្វាយបង្គំព្រះ។ ការស្អាងអាសនា សម្រាប់តង្វាយដុត នឹងតង្វាយមេត្រី រួមទាំតង្វាយ ផ្សេងទៀតត្រូវដាក់អនុវត្ត តាមគោលការណ៍។ ទី៣ នេះគឺជាការស្ដាឡើងវិញនូវកិរិយាល្អ។ ការស្ដារឡើងវិញ គឺជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ និងជាបណ្ដាញនៃព្រះគុណ។

## ៥. ការល្បួងដែលយើងអាចយកឈ្នះបាន

(អែសរ៉ា៦:១-១២) ទោះបីជា ការកសាងឡើងវិញ អាចនឹងត្រូវបញ្ឈប់ដោយ សារ ការចោទប្រកាន់ ពីអ្នកជិតខាងក៏ដោយ ក៏ព្រះបានអនុញ្ញាតឱ្យមាន ការសាកល្បងសមស្រប ដើម្បីធ្វើឱ្យការងាររបស់ព្រះអម្ចាស់ បានរីកចម្រើនដោយព្រះគុណរបស់ទ្រង់។ តើបទគម្ពីរបង្ហាញភស្តុតាងអ្វីខ្លះ? ទី១ ស្ដេចដារីយុសទ្រង់ បានអនុញាតឲថែរក្សាព្រះវិហារ។ (១-៥) ស្ដេចទ្រង់បានចេញ ព្រះរាជឱង្ការ ឲយកគ្រឿងប្រដាប់របស់ព្រះវិហារទៅដាក់នៅកន្លែងធម្មតាវិញ។ ព្រះទ្រង់គឺជា ព្រះដែលមានអំណាចព្រះចេស្ដា ដែលបានសម្រេចបំពេញបំណងព្រះហឫទ័យរបស់ទ្រង់ បើទោះបីជា

ទ្រង់ប្រើប្រាស់សាសន៍ដទៃក៏ដោយ។ ទី២ ពួកគេបានទទួល ការព្រមាន និង ការកំសាន្តចិត្តផងដែរ(១១-១២)។ ស្តេចទ្រង់បានបង្គាប់ឲពួកគេទទួលខុសត្រូវ ផ្គត់ផ្គង់សម្ភារៈរហូតទាល់តែ រួចរាល់ការសាងសង់ព្រះវិហារ។ ហើយក៏ត្រូវដាក់ទោសយ៉ាងធំណំ ដល់មនុស្សណា ដែលមិនគោរពតាមច្បាប់។ ហេតុដែលនាំឲចំពប់នៅមុខគ្រីស្ទាន គឺមានន័យថា ព្រះបានផ្តល់ព្រះគុណច្រើនជាងមុនទៅទៀត។ នេះជាព្រះទ័យដ៏លាក់កំបាំងរបស់ព្រះ។ យើងគួរតែទុកចិត្តដល់ព្រះ ដែលទ្រង់បានអនុញ្ញាតឲមានការពិបាក ហើយបានប្រទានផ្លូវ ដល់យើងដើម្បីរំដោះខ្លួនចេញពីសេចក្តីវេទនានោះ (១កូរិនថូស១០:១៣)។

# មេរៀនទី៣

# ហោរាអែសរ៉ាបានវិលមក ទឹកដីដែលពោពេញដោយបញ្ហា មានប្តីឬប្រពន្ធច្រើន និងបានប្រមូលផ្តុំពួកជំនុំ (អែសរ៉ា ៧:១-១០:៤៤)

## ១. ការរៀបចំដំណើរមនុស្ស (អែសរ៉ា៧:១-១០)

ការសាងសង់ពិតប្រាកដនៃព្រះវិហារ មិនសំដៅទៅលើ ការកសាងផ្នែកខាងក្រៅទេ ប៉ុន្តែផ្តោតទៅលើផ្នែកខាងក្នុងវិញ។ជាការពិត ព្រះគម្ពីរសញ្ញាចាស់ នឹងសញ្ញាថ្មីសង្កត់ធ្ងន់ ផ្នែកខាងក្នុង ចេញពីការសញ្ជឹងគិតទៅលើសារៈសំខាន់ នៃផ្នែកខាងក្នុងរបស់យើង។ គាត់គឺជាកូនចៅជំនាន់ទី១៨ នៃពួកអើរ៉ុន(១៥)។ ឰយុកោរបស់គាត់ Binhas បានបញ្ឈប់ សេចក្តីវេទនាលើពួកអ៊ីស្រាអែល ដោយការថ្វាយ ទង្វើសុចរិតរបស់គាត់ដល់ព្រះ បានធ្វើឲព្រះដកសេចក្តីក្រោធនោះ។ តាមរយៈសកម្មភាពដ៏សុចរិតរបស់គាត់ ព្រះបានរៀបចំកិច្ចការ ប្រវត្តិសាស្ត្រនៃការសង្គ្រោះ។ ទី២ គាត់គឺជាមនុស្សម្នាក់ដែលបានលះបង់ ដើម្បីរក្សាបញ្ញត្តក្រឹត្យវិន័យ។ គាត់ជាមនុស្ស ដែលមានប្រាជ្ញា និងបទពិសោធន៍។ គាត់បានសម្រេចចិត្តថា និងសិក្សាខាងក្រឹត្យវិន័យ ហើយគាត់និងគោរពប្រតិបត្ត ហើយបង្រៀនពីវា នៅក្នុងចិត្តរបស់គាត់វាពិតជាមានតម្លៃណាស់។ នេះបង្ហាញថាគាត់បានទទួលគុណដ៏អស្ចារ្យ។ ទី៣ គាត់បានចាប់ផ្តើមធ្វើកំណែទម្រង់ពីខ្លួនគាត់ផ្ទាល់។ មុនពេលគាត់

បង្រៀនព្រះបន្ទូលរបស់ព្រះ ដួងចិត្តរបស់គាត់ ដែលរក្សាព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរបស់គាត់ មានន័យថា គាត់រៀបចំថ្វាយដល់ព្រះ។

**២.ការខំប្រឹងប្រែងរបស់មនុស្សម្នាក់ (អែសរ៉ា ៧:១១-២៨)**

ការសម្រេចចិត្ត របស់មនុស្សម្នាក់ បានធ្វើរឿងអស្ចារ្យមួយ។ ហោរាអែសរ៉ា បានតាំងចិត្តស្វែងយល់ ពីព្រះបន្ទូលរបស់ព្រះ។ ដោយសារ មានការផ្តល់ អំណាចនយោបាយ និងអំណាចហិរញ្ញវត្ថុ គាត់បានធ្វើការងារ ទាំងអស់ដោយស្រួល ។ តើជំនួយរបស់ព្រះ បានបង្ហាញយ៉ាងដូចម្តេចខ្លះ? ទី១ ព្រះជួយគាត់ រហូតដល់ថ្ងៃនៃការកំណែទម្រង់ទាំងស្រុង ដោយមានការជួយជ្រោមជ្រែង ពីស្តេចអើថាស៊ើកសេស (១១-២២)។ អ្នកណា ដែលស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុន គួរតែបានស្គាល់ព្រះ ហើយនិងបានប្រទានមកអ្នករាល់គ្នាថែមទៀត (ម៉ាថាយ ៦:៣៣)។ ទី២ វាពិតជា អស្ចារ្យណាស់ ដែលមានមនុស្សតាំងចិត្ត ស្វែងរកព្រះបន្ទូលរបស់ព្រះ ពីព្រោះគាត់មានមុខងា ដើម្បីជំរុញពួកគេ សម្រាប់កំណែទម្រង់ ព្រលឹងវិញ្ញាណ និងការសាងសង់ឡើងវិញនៃព្រះវិហារដ៏ពិត។ អស់អ្នកណា ដែលនៅជាប់និងព្រះបន្ទូលរបស់ព្រះ តែងតែរស់នៅជាមួយនិងព្រះគុណដ៏អស្ចារ្យ នឹងអាចប្រើសម្រាប់ការងារថ្វាយព្រះ។ ដូចជាអណ្តាតភ្លើងតូចមួយដុតភ្នំទាំងមូលបាន ដូចជាភ្លើងតូចមួយនៃព្រះបន្ទូលនៅក្នុងចិត្តខ្ញុំ អាចបញ្ឆេះអ្វីៗទាំងអស់នៅលើពិភពលោកបាន។

**៣. កំណែទម្រង់នៃការថ្វាយបង្គំ (អែសរ៉ា ៨:១-២០)**

អែសរ៉ាបាននៅជាប់ នឹងព្រះបន្ទូលរបស់ព្រះ នឹងថ្វាយបង្គំព្រះ។ ការកំណែទម្រង់ពិត មិនគ្រាន់តែស្គាល់ព្រះបន្ទូលនោះទេ ប៉ុន្តែ វាគឺជាការដាក់អនុវត្តក្នុងជីវិត ដើម្បីធ្វើជាមនុស្សដែលស្រលាញ់ការថ្វាយបង្គំ (ម៉ាថាយ២៨:១៨-២០)។ ពួកជំនុំត្រូវតែថ្វាយសិរីរុងរឿងដល់ព្រះ នឹងថ្វាយអំណោយ ដល់ទ្រង់ជារៀងរហូត គឺមានន័យថា ជីវិតគាត់ថ្វាយដល់ព្រះ។ ប៉ុន្តែ សង្ឃណាដែលបានធ្វើការ ក្នុងកិច្ចបម្រើដ៏មានតម្លៃនេះបានបាត់បង់ទៅវិញ។ បន្ទាប់មក ហោរាអែសរ៉ាស្វែងរកមនុស្សសក្តិសម អស់ចំនួនបីថ្ងៃ ហើយដាក់មុខងារអោយគេ។ ទោះបី ពួកលេវី បានចាកចេញនៅពេលនោះក៏ដោយ គាត់បានរកមនុស្សម្នាក់ ដែលប្រកបដោយប្រាជ្ញា សម្រាប់ធ្វើការងារក្នុងព្រះវិហារ(១៦-១៩)។ រួចមកអែសរ៉ាបានប្រកាសប្រាប់ឲមានការតម ប្រយោជន៍ នឹងសូមឲទ្រង់ជួយ(២១)។ យើងថ្វាយបង្គំព្រះ សូម្បីតែពេលយើងកំពុងស្ថិតក្នុងភាពអាក្រក់យ៉ាងខ្លាំងក៏ដោយ ដូច្នេះយើងថ្វាយបង្គំព្រះមិនមែនត្រឹមតែកិរិយាខាងក្រៅទេ ប៉ុន្តែថ្វាយបង្គំព្រះ ដោយវិញ្ញាណនឹងសេចក្តីពិត យើងអាចជួបព្រះបាន(យ៉ូហាន ៤:២៣)។

## ៤.ការសម្រេចចិត្តនៃការផ្លាស់ប្តូរ (អែសរ៉ា ១០:១-១៥)

ដូចជាស្ត្រីសាសន៍សាម៉ារីម្នាក់ ជីវិតរបស់នាងបានផ្លាស់ប្តូរ ដោយសារ ការជួបព្រះយេស៊ូវ ការសម្រេចចិត្តទទួលព្រះយេស៊ូវ ធ្វើឲនាងបានរួចផុតពីទុកវេទនា។ បទគម្ពីរបង្ហាញពី ការផ្លាស់ប្តូរជីវិតរបស់ស្ត្រីម្នាក់ ដែលរស់នៅជាសាសន៍ដទៃ។ តើពាក្យ កំណែទម្រង់ ការផ្លាស់ប្តូរការថ្វាយបង្គំ ការផ្លាស់ប្តូរជីវិតអាពាហ៍ពិពាហ៍ កើតឡើងយ៉ាងដូចម្តេច? ទី១ វាបានលើកឡើង ដោយសាហារឆន្ទះមុះមុតនៃដួងចិត្តរបស់ហោរាអែសរ៉ា។

ភាពស្មោះត្រង់របស់អ្នកដឹកនាំខាងព្រលឹងវិញ្ញាណ ឬការត្រាស់ហៅរបស់គាត់ អាចក្លាយជាបណ្តាញរបស់ការកំណែទម្រង់។ ទី២ ការសម្រេចចិត្តរបស់ប្រជាជននៅក្នុងចិត្ត នាំមកនូវការផ្លាស់ប្រែ។ ដូចដែលជនជាតិអ៊ីស្រាអែល ដើរតាមហិបនៃសេចក្តីសញ្ញាដោយស្ងាត់ស្ងៀម ហើយបានបំផ្លាញទីក្រុងយេរីខូរ។ មនុស្សណាដែលស្តាប់តាមព្រះបន្ទូលព្រះ អាចនឹងស្គាល់កំណែទម្រង់នៃលោកីយ។ ទី៣ កិច្ចការរបស់ ព្រះវិញ្ញាណបរិសុទ្ធ គឺជាចំណុចសំខាន់នៃការកំណែទម្រង់។ ការកំណែទម្រង់ នឹងការកើតឡើងវិញស្ថិតក្រោមអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ តែមួយគត់។ ព្រះមួយអង្គ ដែលជាអ្នកជំនួយ គឺដូចជាវិញ្ញាណទាំង៧ ដែលព្រះបានបញ្ជូនទៅក្នុងលោកីយសម្រាប់កំណែទម្រង់លោកីយនេះ។ យើងត្រូវផ្ទុកឈើឆ្កាងដើម្បីកែប្រែពិភពលោករបស់យើង ដើម្បីទទួលបាននូវការផ្លាសប្រែដ៏អស្ចារ្យ។

## ៥. ការប្រែចិត្តពិតប្រាកដ (អែសរ៉ា ១០:១៦-៥៥)

តាមរយៈបទគម្ពីរបង្ហាញថា មនុស្សសំខាន់ៗ ដែលនៅក្បែរអែសរ៉ា បានប្រព្រឹត្តបាប ច្រើនជាងអ្នកផ្សេងៗទៅទៀត យើងបានរៀនពីសារៈសំខាន់នៃការប្រែចិត្ត។ តើអ្វីជាការប្រែចិត្ត? ទី១ វា គឺជាការរំឭកគាត់ឱ្យទាន់ពេលវេលា។ គាត់នឹងរំឭកពួកគេឡើងវិញ សម្រាប់ ៥ខែម្តង មកគ្រួសាររបស់ពួកគេ។ ការប្រែចិត្ត គឺដូចជាពន្លឺផ្លេកៗ នៅក្នុងជីវិត។ អ្នកដែលពិនិត្យខ្លួនឯងដោយអស់ពីដួងចិត្ត នឹងមានផ្លូវទៅកាន់ក្តីសង្ឃឹម។ ទី២ គាត់ក្រើនរំឭក មនុស្សដែលនៅជុំវិញ។ លើសពីទំនាក់ទំនងត្រឹមជាមនុស្សធម្មតា សមាជិកក្រុមចម្រៀង នឹងពួកសង្ឃត្រូវ ទទួលខុសត្រូវ ក្នុងការថ្វាយបង្គំ។ ការឈរនៅចំពោះព្រះបន្ទូលរបស់ព្រះ គួរតែត្រូវបាន សង្កត់ធ្ងន់ទៅលើជា

និច្ច។ ទី៣ គាត់បានសរសេរស្នាដៃទាំងនោះ។ គាត់បានធ្វើឱ្យពួកគេខិតទៅរកការ ប្រែចិត្តពិត និងការបង្គាប់តាមព្រះបន្ទូលរបស់ព្រះ។ សេចក្តីអំណរដ៏ពិត ត្រូវបានកត់ទុកនៅក្នុងសៀវភៅជីវិត និងសៀវភៅសេចក្តីរំឭក។ យើងគួរត្រេកអរនឹងរង្វាន់ដែលមកពីព្រះ ជាជាងរង្វាន់ក្នុងពេលបច្ចុប្បន្ន។

# មេរៀនទី៤

# នេហេមាវិលមកកាន់ទឹកដីវិញ ហើយគាត់បានកសាងកំផែងក្នុងពេលមានការប្រឆាំងនឹងការសាងសង់ (នេហេមា ១:១-៧:៥)

## នេហេមា

### ១. ការអធិស្ឋានរបស់ហោរានេហេមា (១:១-១១)

អែសរ៉ា គឺជាហោរាស្មោះត្រង់ម្នាក់ ប៉ុន្តែនេហេមា បានជួសជុលកំផែងក្រុង នឹងធ្វើជាគ្រប់គ្រង លើមនុស្សទាំងអស់ ពីព្រោះពួកគេត្រូវការសង់ព្រះវិហារ នឹងកំផែងក្រុងឡើងវិញ ដើម្បីការពារ ការវាយប្រហារ ពីពួកខ្មាំងចូលឈ្លានពាន។ តើនេហេមាជាអ្នកណា ហើយគាត់បានធ្វើការ យ៉ាងដូចម្តេចខ្លះ? ទី១ គាត់ជាមនុស្ស ដែលត្រូវបានរៀបចំ ទុក។ (២-៣) ការព្រួយបារម្ភរបស់គាត់ ពេលដែលឮថាកំផែងនៃក្រុងយេរូសាឡិមបាក់បែងអស់។ គាត់ស្រលាញ់ដែលថាអាណាចក្ររបស់ព្រះសាងសង់បានល្អ ហើយគាត់ក៏បារម្ភដែលវាខូចខាត ដោយសារទឹកចិត្តគាត់ គឺជាប់នឹងបំណងព្រះទ័យព្រះ។ ទី២ គាត់ជាមនុស្ស មានទំនួលខុសត្រូវ នឹងមានការប្រែចិត្ត នៅចំពោះព្រះ នេះហើយគឺគន្លឹះសម្រាប់ដោះស្រាយបញ្ហា។ ទី៣ គាត់ពឹងផ្អែកលើ ព្រះបន្ទូលសន្យានៃព្រះ។ (៥-១១) ការប្រែចិត្តពិតបានកើតឡើង ពេលដែលពួកគេពឹងផ្អែកលើ ព្រះបន្ទូលសន្យានៃព្រះ។ សំណូមអធិស្ឋាន របស់

មនុស្សសុចរិត ដែលព្យាយាមប្រែចិត្ត មានកម្លាំងអស្ចារ្យ។ យើងគួរតែត្រាប់តាម គំរូនៃការអធិស្ឋានរបស់ ហោរានេហេមា។

**២.ការឆ្លើយតបរបស់ព្រះ (នេហេមា ២:១-១០)**

ព្រះបានធ្វើការតាមរយៈស្តេចអើថាស៊ើកសេស ដោយទ្រង់ទតឃើញ ហោរានេហេមា ពេញដោយការថប់បារម្ភ។ តើរឿងនេះកើតឡើងដោយរបៀបណា? ទី១ វាត្រូវបានកើតឡើងដោយសារ ភាពទុក្ខព្រួយរបស់នេហេមានៅចំពោះស្តេច (១-៣)។ ការយកចិត្តទុកដាក់ព្រួយបារម្ភ ដែលនេហេមាន ជួយដល់ដំណើរការ ការងាររបស់ព្រះ។ សេចក្តីព្រួយ និងការខ្វល់ខ្វាយដែលបរិសុទ្ធ អាចចាត់ទុកថាជា ផ្នែកជួយដល់ការងាររបស់ព្រះដែរ។ទី២ វាបានបង្ហាញពីការចាប់អារម្មណ៍យ៉ាងខ្លាំង ដល់ស្តេចសាសន៍ដទៃ (៤-៥) ។ទាំងនេះគឺជាភស្តុតាងនៃការងាររបស់ព្រះ។ គឺដូចជាការអធិស្ឋានតមអាហារ របស់អេសធើរ បានធ្វើឲស្តេចអ័ហាស៊្វេរុសមានព្រះទ័យទន់សន្តោស (អេសធើរ ៥:១-៣)។ តាមរយៈការអធិស្ឋាន ជារៀងរាល់យប់របស់លោកយ៉ាកុប បានធ្វើឲលោកអេសាវទន់ចិត្ត(លោកុប្បត្តិ ៣៣: ៣-៤) ព្រះបានផ្លាស់ប្តូរចិត្តរបស់សត្រូវ នឹងពេញដោយប្រាជ្ញារៀងរៃ ដើម្បីបំពេញបំណងព្រះទ័យទ្រង់។ ទី៣ ព្រះធ្វើការតាមរយៈសេចក្តីជំនឿ។ (៥,៧-៨) ដោយសារ សេចក្តីជំនឿ នេហេមាបានបើកចិត្ត របស់គាត់នៅចំពោះស្តេច នឹងបានទូលសូមស្តេចនូវអ្វីដែលគាត់ចង់បាន ហើយស្តេចក៏បានអនុញ្ញាតឲគាត់។ យើងគួរតែខិតចូលទៅជិតព្រះ តាមរយៈសេចក្តីអធិស្ឋានទូលសូមដ៏ខ្លាំងក្លា។ ការអធិស្ឋានដោយ សេចក្តីជំនឿអាច វើភ្ញុំបាន។

## ៣. ភាពជាអ្នកដឹកនាំរបស់នេហេមា (នេហេមា ២:១១-២០)

ដរាបណា នេហេមាបានមកដល់ក្រុងយេរូសាឡិម ក្នុងរយៈពេលបីថ្ងៃ។នេហេមា បានចាប់ផ្តើមបេសកកម្មរបស់គាត់ដោយពិនិត្យមើលកំផែងទីក្រុងយេរូសាឡិម ក្នុងស្ថានភាពជាក់ស្តែង។ តើគាត់ប្រតិបត្តិយ៉ាងដូចម្តេច? ទី១ គាត់បានប្រាប់ឲដឹងពីបំណងរបស់ព្រះ (១១-១៧) ។ គាត់បានដាស់តឿនថា ពួកគេគួរតែស្តាប់តាមបង្គាប់របស់ព្រះ ដោយប្រាប់ពួកគេឲដឹងពីបន្ទូលរបស់ស្តេច ដែលទ្រង់នឹងផ្គត់ផ្គងទាំងស្រុង មិនថាបញ្ហាលុយកាក់ឬមនុស្ស។ គាត់បានបង្រៀនថា ការដែលយើងធ្វើតាមព្រះហទ័យព្រះ ដោយចុះចូលបំណងរបស់យើង មានន័យ សេចក្តីរុងរឿង។ នេហេមា ធ្វើការទាំងនេះ ដោយស្ម័គ្រពីចិត្ត ជាជាងចិត្តក្លែងក្លាយ។ (១៨) ពួគគេមិនគួរធ្វើតាមបំណងចិត្តគេទេ គឺគួរធ្វើតាមរបៀបរបស់ព្រះ នឹងគោរពតាមការរៀបចំរបស់ព្រះ យើងគួរតែធ្វើជាយញ្ញបូជារស់ ដើម្បីនឹងធ្វើការល្អនោះ។ ទី៣ គាត់ធ្វើការទប់ស្កាត់ភ្លាមៗ ទៅនឹងពួកមនុស្សដែលប្រឆាំងការសាងសង់ព្រះវិហារនៃព្រះយេហូវ៉ា ដើម្បីរក្សាបំណងព្រះហទ័យព្រះនៃស្ថានសួគ៌(១៩-២០)។ ទោះបីជា ការទាស់ប្រឆាំងនោះខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏មិនអាចបំផ្លាញបំណងព្រះហទ័យព្រះបានដែរ។ តាមរយៈព្យុះនៃបញ្ហា ព្រះធ្វើឱ្យពួកវា រលាយបាត់យ៉ាងលឿនជាងមុន។ អ្នកដឹកនាំព្រលឹងវិញ្ញាណ ត្រូវការអាកប្បកិរិយាបែបនេះ។

## ៤. ការកសាងសេចក្តីជំនឿឡើងវិញ (នេហេមា៣:១-៣២)

កំផែងរបស់នេហេមាបានជួសជុល គឺមានទ្វារ៧ (ទ្វារចៀម ទ្វារត្រី ទ្វារអេប្រាអ៊ីម ទ្វារចាស់ ទ្វារអណ្តូង ទ្វារសម្រស់ នឹងទ្វារប៉ម)។ អស់អ្នកណាដែលស្មោះត្រង់ ក្នុងការរក្សាតួនាទីនិមួយៗ ដើម្បីសាងសង់កំផែង (១-២)។ ទី១ យើងគួរសាងសង់កំផែង នៃសេចក្តីជំនឿ ដែលបានបំផ្លាញ។(១-២) យើងគួរតែដឹងពីឧបសគ្គរបស់យើង នឹងដាក់អនុវត្ត ការប្រែចិត្ត និងសេចក្តីជំនឿ។ យើងគួរតែដក ឧបាយកលរបស់សាតាំង និងលោកីយ និងបំណងប្រាថ្នាខាងសាច់ឈាមចេញ ហើយគួរតែបំពេញជាមួយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ ទី២ មានតែព្រះគ្រីស្ទប៉ុណ្ណោះដែលជាកំពែងរបស់យើង។ (យ៉ូហាន ១០: ២៨-២៩) យើងគួរតែរីករាយ នឹងព្រះគ្រីស្ទហើយបង្កើតផលផ្លែជាបរិបូណ៌ ដោយដើរតាមទ្រង់ដោយស្មោះត្រង់។ គ្មាននរណាម្នាក់ អាចដកហូតយើង ចេញពីព្រះហស្តរបស់ទ្រង់បានឡើយ។

## ៥. វិធីដើម្បីយកឈ្នះការល្បួង (នេហេមា ៤: ១-១៤) –

ការងាររបស់ព្រះ ក៏ជួបប្រទះនឹងការល្បួង មួយចំនួនផងដែរ។ ដូចជា សានបាឡាត នឹងថូប៊ីយ៉ា បានចំអកឡកឡឺយ ការងាររបស់ព្រះ។ តើនេហេមាបានយកឈ្នះ យ៉ាងដូចម្តេច? ទី១គាត់បានអធិស្ឋាន (៤) ហើយថ្វាយស្ថានភាពបច្ចុប្បន្នដល់ព្រះ ហើយស្វែងរកជំនួយពីព្រះ។ នៅពេលដែលយើងប្រព្រឹត្តបញ្ហាខ្លះចំពោះព្រះ ហើយបម្រើស្ថានភាពបច្ចុប្បន្ន ដោយភាពសមត្ថរបស់យើង យើងអាចទទួលបានកម្លាំងខ្លះនិងផ្លូវដែលអាចរត់គេចបាន។ (៩) ទី២ គាត់បានលើកទឹកចិត្តកុំឱ្យភ័យខ្លាចវា។ (១៤) គោលដៅរបស់ខ្មាំងសត្រូវ ដែលវាយប្រហារជំនួន ១០ ដងគឺដើម្បីធ្វើឲមានការភិតភ័យ។ បន្ទាប់មក នេហេមា បាននិយាយថា អ្នកមិនត្រូវខ្លាចខ្មាំងសត្រូវរបស់អ្នកទេ

ប៉ុន្តែអ្នករាល់គ្រូវគោរពកោតខ្លាចព្រះអម្ចាស់ជាជាង។ ពេលយើងអានបទគម្ពីរ សញ្ជឹងគិត និងធ្វើតាមព្រះបន្ទូល យើងអាចស្គាល់ព្រះ និងប្រាជ្ញារបស់ទ្រង់ ជាងមនុស្សផ្សេងទៀត។ យើងអាចយកឈ្នះការល្បួងបាន ដោយព្រោះព្រះទ្រង់ស្មោះត្រង់ (១កូរិនថូស ១០:១៣)។

## ៦. កិច្ចការរបស់សេចក្ដីជំនឿ (នេហេមា ៤: ១៥-៥: ៥)

សេចក្ដីជំនឿ ដែលជួបសេចក្ដីវេទនា វានឹងកាន់តែចែងចាំង។ ពួកខ្មាំងសត្រូវ គេគិតគ្នាថា នឹងលោចូលទៅដល់កណ្ដាលគេ រួចសម្លាប់គេបង់ ហើយបញ្ឈប់ការកសាងកំផែងទីក្រុងឡើងវិញ ដោយប្រើប្រាស់មធ្យោបាយជាច្រើន។ តើនេហេមា បានប្រព្រឹត្តយ៉ាងដូចម្ដេច? ទី១ ពួកអ្នកដែលធ្វើកំផែង នឹងពួកអ្នកដែលលីសែង គេធ្វើការដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់គ្រឿងសស្ត្រាវុធ(៤: ១៥-២០)។ បន្ទាប់ពី បំណងព្រះរបស់ព្រះត្រូវបានតាំងឡើង គាត់បានរក្សាវាដោយផ្ទាល់។ អ្វីដែលអ្នកគួរស្វែងរក គឺភាពស្មោះត្រង់ពីព្រោះព្រះអង្គផ្ទាល់ស្មោះត្រង់។ ទី២ គាត់បានដោះស្រាយភាពទាល់ក្ររបស់បងប្អូន ដោយព្រះបន្ទូលរបស់ព្រះ។ (៥: ១-៥) លោកបានកាត់បន្ថយ គម្លាតខុសគ្នារវាង អ្នកមាននិងអ្នកក្រ ដោយធ្វើតាមព្រះបន្ទូព្រះ ពីព្រោះជំនឿនៃការកោតខ្លាចដល់ព្រះអម្ចាស់ រួមបញ្ចូលទាំងសេចក្ដីមេត្តាករុណា។ តាមរយៈព្រះបន្ទូល ក្ដីជំនឿពិត បង្កើតផលផ្លែល្អ។ ពេលដែលយើងតោងជាប់ជំនឿនេះ យើងអាចនឹងកាន់តែ      រីកចម្រើន។

## ៧. ភាពជាអ្នកដឹកនាំនៃការបម្រើ (នេហេមា ៥: ៦-១៩)

នេហេមា បានបង្ហាញភាពជាអ្នកដឹកនាំ ក្នុងការបម្រើ។ ទី១ គាត់បានសង្កត់ធ្ងន់ទៅលើ សេចក្តីស្រឡាញ់របស់បងប្អូន។ (៦-៩) គាត់ហាមឃាត់មិនឱ្យនរណាម្នាក់ ដាក់បន្ទុកដល់អ្នកក្រីក្រឡើយ។ នៅក្នុងការប្រជុំ គាត់បានស្តីបន្ទោសពួកគេ ដោយធ្វើឱ្យពួកគេស្គាល់ ទង្វើរដែលមិនត្រឹមត្រូវដែលប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះ។ មនុស្សលោភលន់ មិនអាចក្លាយជាអ្នកដឹកនាំដ៏ពិតបានទេ។ ទី២ ទ្រង់បានដាស់តឿនថា អ្នកណាដែលមើលងាយបងប្អូន សមនឹងទទួលទុកវេទនា។ (១៣) ពីព្រោះបទបញ្ញត្តិនៃសេចក្តីស្រឡាញ់ គឺជាផលផ្លែនៃសេចក្តីកោតខ្លាចដល់ព្រះអម្ចាស់។ ទី៣ គាត់ចាត់ទុកការងារ សម្រាប់ព្រះគឺសំខាន់បំផុត នេះហើយជាមូលហេតុដែលគាត់បដិសេធខ្លួនឯង។ គាត់មិនបានមើលងាយសិទ្ធិ របស់អភិបាលទេ ហើយបានបង្ហាញពីគំរូ នៃមនុស្សដែលមិនស្មោះត្រង់អំពីលុយ (១៥-១១៦ ១៨)។ សាវ័កប៉ុល បានដាស់តឿន ពីការដែលលោភចង់បានប្រាក់ មាសរបស់អ្នកណាម្នាក់ (កិច្ចការ ២០:៣៣)។ អ្នកណា ដែលកោតខ្លាចដល់ព្រះយេហូវ៉ា ទ្រង់នឹងចងចាំពួកគេ។ យើងគួរតែត្រូវបានគ្រង ដោយរបស់ទាំងនេះនៅក្នុងជីវិតរបស់យើង។

## ៨. នៅពេលដែលយើងជួបនឹងអ្នកមិនជឿ (នេហា ៦: ១-១៤)

ខ្មាំងសត្រូវ យាយីការកសាងកំផែងសារជាថ្មី។ ចំពោះការប្រឆាំងរបស់ សានបាឡាត នឹងថូប៊ីយ៉ា ព្រមទាំងកេសែម តើនេហេមា បានទប់ទល់នឹងពួកគេយ៉ាងដូចម្តេច? ទី១ គាត់រក្សាក្នុងសភាពស្ងៀមស្ងាត់ (១០) ។ ពួកគេបាន  អញ្ជើញនេហេមា មកពិគ្រោះចំនួន ៥ដង(៤-៥) តែគាត់មិនបានទៅប្រទល់មុខ ដោយផ្ទាល់ជាមួយពួកគេទេ គឺគាត់បានគេចេញវិញ។ ទី

បំផុត គាត់បានយកឈ្នះរាល់ពាក្យចចាមអារាម ដែលអាក្រក់ ក្នុងសភាពស្ងៀមស្ងាត់។ ទោះបី ពួកគេបានរៀបគម្រោងការបោកប្រាស់ ដោយជួលគេ ៤ ទាយទំនាយទាស់ នឹងគាត់ក៏ដោយ ក៏គាត់នៅតែយកឈ្នះបាន ដោយសារការទូលសូមដល់ព្រះយេហូវ៉ា។ ទី២ គាត់បានឃើញថា ព្រះទ្រង់អស្ចារ្យណាស់។ (១០) ពួកមនុស្សអាក្រក់ គេផ្តោតទៅលើកិច្ចការ ដែលពួកគេបានធ្លាក់ចូលទៅក្នុងការរារាំងវិញ។ នៅពេលដែលគាត់បានឃើញ ភាពអស្ចារ្យរបស់ព្រះ ការរារាំងត្រូវបានដកចោលភ្លាមៗ។ យើងត្រូវតែយកឈ្នះការរារាំងរបស់សាតាំង នឹងការខកចិត្ត ដោយសារសេចក្តីជំនឿ នឹងការសម្លឹងមើលទៅព្រះ។

## ៩. អំណាចនៃកិច្ចការរបស់ព្រះ (នេហេមា ៦: ១៥-៧: ៤)

ក្នុងរយៈ ៥២ថ្ងៃកំផែងបានសង់ឡើងជាស្រេច តើមានលទ្ធផល ជាយ៉ាងណា? ទី១ ខ្មាំងសត្រូវ ត្រូវបានវិនាស (៦:១៦) ។ទោះបីជា មានបញ្ហាជាច្រើនបានកើតឡើងតាមរយៈបំណងចិត្តរបស់ពួកគេក៏ដោយ ក៏ភាពពេញលេញនៃកំផែង ក្នុងរយៈពេលខ្លី ធ្វើឱ្យពួកគេមិនសប្បាយចិត្ត។ ពួកគេបានចុះចាញ់ចំពោះ ព្រះហស្តដ៏ខ្លាំងអស្ចារ្យរបស់ព្រះ។ ជ័យជំនះនៃសង្គ្រាមនេះជាកម្មសិទ្ធរបស់ព្រះហស្តរបស់ព្រះយេហូវ៉ា ហើយពួកខ្មាំងសត្រូវ ទាំងអស់នឹងត្រូវកំទេចចោល។ ទី២ ជំនឿដ៏អស្ចារ្យ នៃការកោតខ្លាចដល់ព្រះយេហូវ៉ាត្រូវបានបង្ហាញឱ្យឃើញ (៧: ២); អ្វីដែលគាត់កាន់ក្នុងកិច្ចការលំបាកនេះ គឺជាសេចក្តីជំនឿ នៃការកោតខ្លាចដល់ព្រះយេហូវ៉ា។ នៅពេលដែលអំណាចត្រូវបានដឹងដល់ ពួកសត្រូវ ពួកគេមានការភ័យខ្លាចយ៉ាងខ្លាំងនៅក្នុងចិត្ត។ គឺដូចគ្នាទៅនឹងសេចក្តីសង្គ្រោះ ដែលព្រះបានធ្វើ នៅពេលទ្រង់បានញែក

ទឹកសមុទ្រក្រហម ហើយពួកសត្រូវបានវិនាសអស់ទៅ។ ប្រជារាស្ត្ររបស់ព្រះ បានសរសើរតម្កើងព្រះជាម្ចាស់ ពីព្រោះពួកគេបានទទួលការគោរពកោតខ្លាចដល់ទ្រង់ និងអរព្រះគុណទ្រង់ (និក្ខមនំ ១៤: -១៥: យោង)។

## ១០. ជំរឿនប្រជាជនយូដាដែលវិល ត្រឡប់មកស្រុកវិញ (នេហេមា ៧: ៥-៧៣)

តើយើងបានរៀនពីសេចក្តីកត់ទុកក្នុងបញ្ជី ពីការវិលត្រឡប់របស់ពួកអ្នកស្រុកយូដា អ្វីខ្លះ។ ទី១ កិច្ចការរបស់ព្រះ បានចាប់ផ្តើមដោយព្រះវិញ្ញាណបរិសុទ្ធ នឹងដោយអំណាចនៃព្រះវិញ្ញាណ។ (៥) យើងបានរកឃើញថាព្រះអង្គផ្ទាល់ បានសម្រេចបំពេញ ពាក្យទំនាយ តាមរយៈនេហេមាធ្វើការងារទាំងនោះ ក្នុងពេលវេលាដែលពិបាក។ ទី២ សរុបចំនួនមនុស្ស ៤២.៣៦០ នាក់ត្រូវបានគេរាប់ យោងទៅតាមពង្សាវតា ដោយមិនគិតពីឋានៈខ្ពស់ឬទាប។ មានអំណោយទានជាច្រើនបានបង្ហាញ បង្ហាញពីចំនុច រួមបញ្ចូលគ្នា ធៀបពួកជំនុំពិត។ ពួកគេគឺជាពួកជំនុំក្នុងព្រះគម្ពីរសញ្ញាចាស់។ ពួកជំនុំគួរតែល្វូតលាស់ ដូចជាពួកជំនុំរបស់ព្រះ ដែលជាចំនុចកណ្តាល នៃការតាំងសញ្ញារបស់ព្រះ ដោយការជឿ នឹងការស្គាល់ ដែលមានអំណរសុចរិត មេត្រី ហើយនឹងភាពរីករាយរបស់នគរព្រះ ពីព្រោះនេះជាបំណងរបស់ព្រះ។ (អេភេសូ ៤:១៣)

# មេរៀនទី៥

# ការប្រារព្ធពិធីសម្រាប់ដំណាក់របស់ព្រះ

# (នេហេមា ៧:៧៣-១៣:៣១)

## ១.ការចាប់ផ្តើមនៃការកើតឡើងវិញ (នេហេមា ៨:១-៨)

បទគម្ពីរបានបង្ហាញពី ការកកើតឡើងជាថ្មីដ៏អស្ចារ្យ នៅពេលប ណ្តាជនទាំងឡាយមូលគ្នាមក នៅទីធ្លាដែលដែលនៅមុខទ្វារទឹក ដោយមានចិត្តតែមួយ នោះលោកក៏អានមើលក្នុងគម្ពីរនោះ នៅមុខគេទាំងអស់គ្នា។ តើវាគឺជាអ្វី? ទី១ ពួកគេបានរៀបចំការអធិស្ឋាន។ ដោយពួកគេមានចិត្តតែមួយ ហើយ ប្រមូលផ្តុំ ចង់ស្តាប់ព្រះបន្ទូលរបស់ព្រះ គឺជាកិច្ចការរបស់ព្រះ។ (១) នេះជាអំណោយទាន របស់ពួកបរិសុទ្ធ ដែលពួកគេបានអធិស្ឋានដល់ព្រះ ដោយស្មោះត្រង់ នៅកន្លែងសម្ងាត់។ ទី២ ពេលដែលពួកគេបានស្តាប់ ព្រះបន្ទូនៃការរស់រៀនជាថ្មីបានកើតឡើងម្តងទៀត។ (៣) ហើយចាប់តាំងពីព្រលឹម ដរាបដល់ថ្ងៃត្រង់ នោះលោកក៏អានមើលក្នុងគម្ពីរនោះ ឯបណ្តាជនទាំងឡាយ គេក៏ផ្ទៀងត្រចៀក  ស្តាប់ ក្នុងគម្ពីរក្រឹត្យនោះ ហើយបានប្រែចិត្តពីអំពើបាបរបស់គេ។ ព្រះបន្ទូលរបស់ព្រះ មានអំណាចពីព្រោះ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការតាមរយៈ ព្រះបន្ទូលរបស់ព្រះ។ ដាវរបស់ព្រះវិញ្ញាណ គឺជាព្រះបន្ទូល (អេភេសូ ៦:១៧)។ទី៣ នៅពេលដែលពួកគេ បានបង្ហាត់បង្រៀន ព្រះបន្ទូលរបស់ព្រះ យ៉ាងល្អិតល្អន់ ដល់បណ្តាជន។ (៨-៩) ជាមួយនឹង ការប្រែចិត្តរបស់ពួកជំនុំ សង្ឃដែលបានរៀន ព្រះបន្ទូល

របស់ព្រះ ដោយការបង្ហាត់បង្រៀនរបស់អែសរ៉ា បានពន្យល់ស្រាយន័យសេចក្តី ឲគេបានយល់ពីបទគម្ពីរ ដែលបានអាននោះ។ (៧) ភ្លើងនៃព្រះវិញ្ញាណធ្វើការ។ យើងគួរតែ ព្យាយាមលះបង់ខ្លួនឯង ហើយទៅបញ្ចុះបញ្ចូល ឲ្យមានសិស្ស។ (ម៉ាថាយ ២៨: ១៩-២០ ធីម៉ូថេទី ២ ២: ២)។

## ២. ភស្តុតាងនៃការរួបរួមឡើងវិញ (នេហេមា ៨: ៩-១៨)

ប្រវត្តិសាស្ត្រនៃការរួបរួមឡើងវិញជាបណ្តាញ តើចំនុចអ្វីខ្លះដែលមានលក្ខណៈដូចទៅនឹង ការរួបរួមឡើងវិញនាសម័យកាល ពួកជំនុំដំបូង? ទី១ ពួកគេមានចិត្ត ចង់ស្គាល់ ព្រះបន្ទូលរបស់ព្រះយ៉ាងច្បាស់។ (១១-១២) លក្ខណៈនៃការរួបរួមជាថ្មី របស់ពួកជំនុំដំបូង មានដូចជា ការទទួលយក ការបង្រៀនរបស់សាវ័ក ការតាំងចិត្តអធិស្ឋាន នឹងការប្រកបជាគ្នាជាដើម។ ការទទួល ព្រះបន្ទូលរបស់ព្រះ ជាភស្តុតាងនៃការរស់ឡើងវិញ។ (កិច្ចការ ២: ៤២-៤៧) ហើយពួកគេ មានបំណងចង់ស្គាល់បទគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះ។ ទី២ សកម្មភាពដែលព្យាយាម ស្មោះត្រង់នឹងព្រះបន្ទូលរបស់ព្រះ។ (១៤-១៨) ហើយការតំឡើង ត្រសាលនោះ បង្ហាញពីការធ្វើតាមបង្គាប់ព្រះ។ ការធ្វើពិធីបុណ្យបារាំ បង្ហាញពីភាពស្មោះត្រង់ របស់ពួកគេ ទៅនឹងព្រះបន្ទូលព្រះ។ ការរួបរួមឡើងវិញ បង្ហាញពីសេចក្តីជំនឿស៊ុប ដែលរស់នៅដោយពឹងផ្អែកលើបទគម្ពីរ។ ទី៣ ពួកជំនុំបរិសុទ្ធ ត្រូវបានសម្តែងចេញមក។ ការលះបង់ពួកគេ ដើម្បីប្រមូលផ្តុំគ្នា គឺជាភស្តុតាងនៃការរួមរស់ឡើងវិញ ពីព្រោះ ពួកគេដឹងថា ព្រះទ្រង់ល្អណាស់ ព្រះបន្ទូលរបស់ទ្រង់ មានតម្លៃដែលមិនអាចកាត់ថ្លៃបាន។ ដោយចេញពីជម្រៅចិត្តរបស់ខ្ញុំ គឺគួរតែមានការរួបរួមជាថ្មីកើតឡើងបែបនេះ។

## ៣. ការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ (នេហេមា ៩: ១-២២)

ការរួបរួមជាថ្មីកើតឡើង ដោយសារបណ្តាជនតមអាហារ ការប្រជុំជំនុំមុតមាំ ការញែកខ្លួនចេញពីសាសន៍ដទៃ រួចត្រឡប់មកថ្វាយបង្គំព្រះវិញ។ មានការឆ្លើយតប ចំនួនពីរ ជាពិសេសបានកើតឡើង។ ទី១ ការបន្លឺសំឡេងអំពាវនាវដល់ព្រះយេហូវ៉ាជាព្រះនៃខ្លួន ។ (៤) ការអំពាវនាវរបស់សង្ឃទាំង៨នាក់ នឹងមេដឹកនាំរបស់ប្រជាជនបានក្រោកឡើងនៅលើអាសនា ហើយស្រែកចេញមក ដោយមានការនាំមុខពីព្រះវិញ្ញាណបរិសុទ្ធ ពីព្រោះកិច្ចការរបស់ព្រះ ចាប់ផ្តើមជាមួយព្រះវិញ្ញាណបរិសុទ្ធ នឹងសម្រេចបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណ ដែលបានចូលរួមការបង្កើត (លោកុប្បត្តិ ១:២) ព្រះវិញ្ញាណដដែលបានធ្វើលើការកកើតជាថ្មី ។ (កិច្ចការ ២: ១៧-២១) ទី២ ដោយចងចាំពីអតីតកាល ពួកគេបានសរសើរព្រះ។ (៥) នៅពេលដំបូង ព្រះដែលបានយាងចុះនៅលើភ្នំស៊ីណាយ បានដឹកនាំជនជាតិអ៊ីស្រាអែល នៅក្នុងជីវិតនៅទីរហោស្ថាន ដោយព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បានប្រទានព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់ ក្នុងខ ២០ ពួកគេទទួលបានការការពារ នឹងបំពេញរាល់តម្រូវការដោយព្រះវិញ្ញាណ។ ក្រោយមកសាវ័កប៉ុលបានពន្យល់ថា ព្រះគ្រីស្ទ បានគង់ជាមួយពួកអ៊ីស្រាអែល ក្នុងទីរហោស្ថាន។ (១ កូរិនថូស ១០: ១-៤) ហើយនៅតាមផ្លូវដែល វិលត្រឡប់មក ពីប្រទេសបាប៊ីឡូន ព្រះត្រៃឯកគង់នៅជាមួយពួកគេ ហើយដឹកនាំគេ។ យើងគួរតែទទួលយក ការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ គ្រប់ស្ថានភាព។

## ៤. ព្រះដ៏ស្មោះត្រង់ (នេហេមា ៩: ២៣-៣៧)

តើព្រះទ្រង់ បានដឹកនាំជនជាតិអ៊ីស្រាអែល នឹងពួកជំនុំទីរហោស្ថាន ដឹកនាំពួកគេក្នុងការជិះជាន់របស់បាប៊ីឡូនយ៉ាងដូចម្តេច? ទី១ ព្រះបាន ដឹកនាំពួកគេ ដោយរក្សាសេចក្តីតាំងសញ្ញាយ៉ាងស្មោះត្រង់។ ពេលខ្លះដោយ ការអស្ចារ្យ (២១) ពេលខ្លះដោយការរងទុក្ខវេទនា (២៩-៣០) ដើម្បីរៀន សូត្រពីការស្តាប់បង្គាប់ បែបជាពាស្រ្តរបស់ព្រះ។ ទី២ វាត្រូវបានបង្ហាញ ដោយ ការរក្សាសេចក្តីស្រឡាញ់ យ៉ាងស្មោះត្រង់។ ព្រះយេហូវ៉ា បានដឹកនាំ ពួកគេ ដោយ សេចក្តីស្រឡាញ់ និងសេចក្តីពិត។ ទោះបីពួកគេ ទទួលបាន ព្រះគុណដ៏អស្ចារ្យក៏ដោយ ក៏ព្រះបានបង្ហាញសេចក្តីស្រឡាញ់ដល់ពួកគេ ដែលមានលក្ខណផ្លាស់ប្តូរគ្រប់ពេល។ ជាចុងក្រោយ ព្រះបានប្រទានព្រះ រាជបុត្រាទ្រង់ តែមួយដល់ពួកគេ ហើយធ្វើអោយពួកគេ ក្លាយជាកូនក្រមុំ ដែលស្រឡាញ់តែព្រះ។

## ៥. ការស្តារឡើងវិញនៃការតាំងសញ្ញា (នេហេមា ១០: ១-៣៩)

តើឈ្មោះពួកអ្នកដែលបោះត្រា ដោយការតាំងសញ្ញា បានកត់ទុក នឹងរក្សាទុកសម្រាប់បង្រៀន យើងអ្វីខ្លះ? ទី១ យើងរៀនអំពីសារៈសំខាន់ នៃ ការលះបង់របស់អ្នកដឹកនាំ ដែលពេញដោយព្រះវិញ្ញាណ។ (១០-២៧) ពួក ថៅហ្វាយ ពួកសង្ឃ នឹងពួកលេវី ដែលនៅចំពោះ នេហេមាត្រូវបាន ចុះហត្ថ លេខា ឲពួកគេ។ កិច្ចការរបស់ព្រះ ត្រូវបានសម្រេចបំពេញ ដោយមនុស្ស ដែលមានការលះបង់បូជា។ ជីវិតដែលបានថ្វាយដល់ព្រះ អស់ពីចិត្ត គឺជា ជីវិតពេញដោយព្រះពរ។ (២៨-៣៩) ទី២ ខ្លឹមសារនៃការតាំងសញ្ញាដំបូង មានដូចជា សេចក្តីបង្គាប់នៃការរៀបអាពាហ៍ពិពាហ៍ ការរក្សាថ្ងៃឈប់ សម្រាក ការថ្វាយតង្វាយមួយភាគដប់។ល។ ត្រូវបានបដិសេធជាថ្មីម្តងទៀ

ត។ (២៨-៣៩) វិធីដែលរក្សាព្រះឱ្យបានល្អ គឺមិនត្រូវបន្ថែមរបស់អ្វីថ្មីទៀតទេ ប៉ុន្តែស្តារឡើងវិញ នូវសេចក្តីសន្យាដំបូងហើយរក្សាវាយ៉ាងស្មោះត្រង់។ ចំនុចដែលពួកជំនុំអេភេសូ ត្រូវបានបន្ទោស គួរតែត្រូវដាក់អនុវត្ត រាល់ស្ថានការណ៍។ (វិវរណៈ ២:៥) យើងគួរតែរស់នៅ ជាមនុស្សម្នាក់ ដែលតាំងចិត្តស្វែងយល់ ពីការតាំងសញ្ញានៃសេចក្តីស្រឡាញ់ដំបូង។

## ៦. ទំនួលខុសត្រូវនៃការតាំងទីលំនៅ (នេហេមា ១១: ១-១២: ២៦)

យើងរៀនបាន២ចំនុច ចេញពីបទគម្ពីរ ដែលសម្គាល់ពីបញ្ជីរាយនាម របស់អ្នកតាំងទីលំនៅសាជាថ្មី នៅក្រុងយេរូសាឡិម ពួកសង្ឃនឹងពួកលេវី។ ទី១ មេដឹកនាំពួកជំនុំ ឲពួកគេតាំងទីលំនៅ ដើម្បីផ្តល់ការទទួលខុសត្រូវដល់ប្រជាជនផ្សេងទៀត (១១: ២០-២២) ពីព្រោះដើម្បីជួយការពារទំនាក់ទំនងត្រឹមត្រូវ ដែលគឺជាជីវិត របស់ពួកជំនុំ។ ទី២ ប្រជាជានបិតនៅឯ ទីក្រុងផ្សេងទៀត គួរតែលះបង់ នឹងរស់នៅតាមរបៀបបង្រៀនរបស់ពួកគេសម្រាប់ប្រជាជននៃក្រុងយេរូសាឡិម។ (១២: ១-២៦) ហើយនេះគឺជាស្រមោលនៅ ពួកជំនុំ នៅក្នុងគម្ពីរសញ្ញាចាស់ ទទួលព្រះគុណរបស់ព្រះ ហើយវាផ្តោតទៅលើ ព្រះគុណរបស់ព្រះ នៅក្នុងពួកជំនុំ គម្ពីរសញ្ញាថ្មីវិញ។ ពួកជំនុំក្នុងព្រះគ្រីស្ទ មានទំនួលខុសត្រូវ ក្នុងការរស់នៅជាចំនុចកណ្តាលនៃព្រះគ្រីស្ទ នឹងរីករាយនឹងអភ័យឯកសិទ្ធ ដែលរីករាយនឹងព្រះគុណនៃសេចក្តីសង្គ្រោះដ៏លើសលប់។ ក៏មានតួនាទី ទៅប្រកាសពីដំណឹងល្អ នៅក្នុងលោកកីយផងដែរ។ យើងគួរតែបង្ហាញពី ផលផ្លែនៃការផ្សាយដំណឹងល្អ។

## ៧. ការទទួលយកតង្វាយ (នេហេមា ១២: ២៧-៤៧)

តើពិធីឆ្លងកំផែងក្រុងយេរូសាឡិម ក្នុងភាពស្ងប់ស្ងែងដ៏អស្ចារ្យ ដែលបានសម្រេចបំពេញ ដោយបំណងព្រះរបស់ព្រះ យ៉ាងដូចម្តេចខ្លះ? ទី១ វាគឺជាស្នូលនៃចំណុចសំខាន់។ (១៧-២៩, ៣៦-៣៨) គាត់បានធ្វើឱ្យពួកគេប្រតិបត្តិ ការថ្វាយបង្គំដ៏អស្ចារ្យ នៅឯពិធីឆ្លង ជាមួយនឹងការសរសើរដោយអំណរ និងអរព្រះគុណ។ វាគឺជាភស្តុតាង នៃការផ្សះផ្សាឡើងវិញជាមួយព្រះ។ ទី២ វាជាភាពបរិសុទ្ធ ជាស្នូលជីវិត។ (១៧) គាត់បានផ្តល់ភាពចាំបាច់ឲពួកគេ ដោយផ្តោតលើភាពបរិសុទ្ធ ដោយសមាជិកក្រុមចម្រៀង ឆ្មាំរក្សាទ្វារ ពួកសង្ឃ នឹងពួកលេវី ក្នុងជីវិតប្រចាំថ្ងៃ។ ដូច្នេះពួកគេបានរក្សា ភាពបរិសុទ្ធ ជាស្នូលជីវិត។ នៅពេលដែលយើងសញ្ជឹងគិតពីភាពបរិសុទ្ធ នឹងភាពសុខសាន្ត ព្រះគឺគួរតែត្រូវបានទទួលយក ហើយយើងគួរតែដើរតាមផ្លូវដែលមិនមែនគ្រាន់តែ ជារូបភាពខាងក្រៅ ប៉ុន្តែគឺជាជីវិតផ្នែកខាងក្នុង នៅចំពោះព្រះដ៏មើលមិនឃើញ។ (១៩:១៤) យើងគួរតែតាំងចិត្តស្វែងរកសេចក្តីមេត្រី ហើយឲបានញែកជាបរិសុទ្ធ (ហេព្រើរ ១២:១៤)។

## ៨.មេដឹកនាំត្រូវស្អាងភាពបរិសុទ្ធ (នេហេមា ១៣:១១-៩)

បន្ទាប់ពី ពិធីឆ្លងបានបញ្ចប់ ការថ្វាយតង្វាយ ដើម្បីឲពួកគេបានបរិសុទ្ធ បានបន្តថ្វាយឥឈប់ឈរ។ តើគំរូពីការស្មោះត្រង់របស់នេហេមាបានបង្ហាញយ៉ាងដូចម្តេច? ទី១ យើងត្រូវតែកាន់ខ្ជាប់ ព្រះបន្ទូលរបស់ព្រះដូចជាខ្នាតគំរូនៃសេចក្តីសុចរិត។ (១-៣) គាត់បានដាក់អនុវត្ត បញ្ញត្តនៃក្រឹត្យវិន័យរបស់លោកម៉ូសេ ដោយផ្ទាល់សម្រាប់កិច្ចការបច្ចុប្បន្ន។ ពួកគេបានហាមឃាត់មិនបណ្តាជន មិនត្រូវប្រព្រឹត្តតាមរបៀប ពួកសាសន៍អាំម៉ូន នឹងពួកសាសន៍ម៉ូអាប់ ហើយនឹងបាឡាមឡើយ គឺត្រូវធ្វើតាមបំណងរបស់ព្រះវិ

ញ។ អស់អ្នកណាដែលស្រេកឃ្លាន សេចក្ដីសុចរិកនឹងមានពរពិត។ ទី២ គាត់បានសាងសេចក្ដីសុចរិតយ៉ាងតឹងរ៉ឹង។ (១៧) នេហេមាមិនបានចូលរួមនៅកន្លែងនោះទេ ហើយគាត់ក៏មិនបានព្រងើយកន្តើយ នឹងរឿងរ៉ាវដែលបានកើតឡើងដែរ។ គឺគាត់បានធ្វើការវិនិច្ឆ័យដោយសុចរិត។ គាត់បានសាង ភាពសុចរិតជាផ្លូវការ ដោយកាត់ផ្ដាច់ការភ្ជាប់ញាតិដែល អេលីយ៉ាស៊ីបដ៏ជាសង្ឃ បានរៀបចំបន្ទប់ធំ១ ទុកសម្រាប់ថូប៊ីយ៉ា។ វាមិនអាចទៅរួចទេ បើមិនបានស្វែងរកព្រះ និងនគររបស់ព្រះអង្គជាមុន (ម៉ាថាយ ៦:៣៣)។

## ៩. កំណែទម្រង់ដែលពិត (នេហេមា ១៣: ១៥-៣១)

តើឧទាហ៍អ្វីខ្លះដែលបទគម្ពីរបានបង្ហាញថា ព្រះបើកសេចក្ដីសុចរិតរបស់ទ្រង់ តាមរបៀបជាច្រើនបង្ហាញមកកាន់យើង? ទី១ នៅថ្ងៃឈប់សម្រាក ពួកជំនុំរបស់ព្រះ ត្រូវហាមឃាត់មិនឲ ធ្វើកិច្ចការផ្ទាល់ខ្លួនឡើយ តែពួកគេនៅតែដឹកកណ្ដាប់ស្រូវ ជាន់ធុងផ្លែទំពាំងបាយជូរ នៅថ្ងៃឈប់សម្រាក។ (១៥-១៨) គាត់ចង់ឲពួកគេ ធ្វើតាមបញ្ញត្តនៃការបង្កើត ដោយការថ្វាយបង្គំព្រះ ដើម្បីទទួលបានសេចក្ដី សម្រាកដល់ព្រលឹង។ ទី២ ការរៀបការ ជាមួយសាសន៍ដទៃ ត្រូវបានហាមឃាត់។ (២៣-២៨) នេហេមាបានឃើញថា សូម្បីតែសម្ដេចសង្ឃ បានឲកូនស្រីគេ ទៅសានបាឡាត។ គាត់បានមើលងាយ តំណែងរបស់គាត់ ក្នុងការរក្សាភាពបរិសុទ្ធរបស់ពួកអ៊ីស្រាអែល។ ទី៣ សំខាន់បំផុតពួកគេត្រូវបានបង្រៀន ដោយការរក្សា ការថ្វាយជីវិតដោយស្មោះត្រង់។ (១៣) ការកំណែទម្រង់ពិត មិនបានបញ្ចប់នូវកិច្ចការអវិជ្ជមានទេ តែជាកិច្ចការនៃភាពវិជ្ជមានវិញ។

# មេរៀនទី៣

# ពិភពលោករបស់អេសធើរ

**១. ការស្វាបស្វង់មតិ**

ក. ភាពជាស្ដេចក្នុងអស់ទាំងសាសន៍

ខ. ថ្វីត្បិតតែព្រះគម្ពីរអេសធើរគ្មានពាក្យ (ព្រះ) ក៏ដោយក៏ព្រះហស្ដនៃការ ការពាររបស់ព្រះតែងតែធ្វើការដែរ។

គ. ឧបាយកលរបស់សាតាំងក៏ជា ឧបករណ៍ដើម្បីសំរេចកិច្ចការរបស់ព្រះ ផងដែរ

ឃ. ព្រះជាម្ចាស់ រំដោះរាស្ដ្ររបស់ព្រះអង្គ អោយរួចផុតពីអំពើទុច្ចរិតគ្រប់ យ៉ាង

ង. ការអធិស្ឋាន អាចផ្លាស់ប្ដូរអ្វីៗទាំងអស់បាន

ច. មារសាតាំង នឹងត្រូវវិនាស ដោយសារទ្រង់។

ឆ. ព្រះបានបំផ្លាញ សេចក្ដីស្លាប់នៃរាស្ដ្ររបស់ទ្រង់។

ជ. ប្រជារាស្ដ្ររបស់ព្រះ គួរតែតាំងចិត្តដើម្បីប្រយុទ្ធប្រឆាំងនឹងខ្លួនឯង។

ឈ. ម៉ាដេកាយ គឺជាស្រមោលនៃព្រះគ្រីស្ទ។

**២. លក្ខណៈពិសេស**

ក) នាងអេសធើរ គឺជាកណ្ឌគម្ពីរពិសេស នៃព្រះគម្ពីរសញ្ញាចាស់។ ថ្វីត្បិតតែកណ្ឌគម្ពីរ នេះមិនបានកត់សម្គាល់ពីព្រះ នឹងការអធិស្ឋានថ្វាយបង្គំព្រះ ក៏ដោយ ក៏ព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះបានបន្តធ្វើការ ក្នុងសាសន៍ដទៃដែរ។

ខ) មានអ្នកខ្លះបាននិយាយថា កណ្ឌគម្ពីរអេសធើរ មិនបានបង្ហាញពីការស្តារឡើងវិញនូវ ពួកជំនុំក្រុងយេរូសាឡិមទេប៉ុន្តែជារឿងរបស់ជនជាតិយូដា ដែលរស់នៅក្នុងសាសន៍ដទៃ។

គ) Maimonide (១១៣៥-១២០៤ គ.ស) កណ្ឌគម្ពីរអេសើរ មានសារៈសំខាន់បន្ទាប់ គម្ពីរក្រឹត្យវិន័យរបស់លោកម៉ូសេ។

ឃ) លូធើរ - ខ្ញុំគិតថាពួកគេមិនបានចាកចេញទេ។ ពីព្រោះពួកគេមានទំនោរទៅក្នុងសង្គមពួកយូដា ហើយជនជាតិយូដាជាច្រើនគឺមិនត្រឹមត្រូវទេ។

ង) Jamnia (១០០) សៀវភៅនេះមានធាតុផ្សំនៃព្រះគម្ពីរ។

## សេចក្តីផ្តើម

រហូតមកដល់ពេលនេះ យើងបានពិនិត្យមើល ពីរបៀបនៃការស្តារឡើងវិញ នូវរូបឆ្លុះរបស់ព្រះ ត្រូវបាន សម្តែងតាមរយៈសកម្មភាពរបស់ស្តេច ការងារជាសង្ឃ នឹងជាហោរាក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល ក្នុងចំណោមប្រវត្តិសាស្ត្រ នៃសៀវភៅប្រវត្តិសាស្ត្រ នៃព្រះគម្ពីរសញ្ញាចាស់។ តាមរយៈកណ្ឌគម្ពីរអេសធើរ ឥឡូវនេះយើងសង្កេតឃើញពី របៀបដែលព្រះបានធ្វើការនៅប្រទេសដទៃ នៅពេលជនជាតិអ៊ីស្រាអែល ត្រូវគេចាប់យក

ទៅ និងរស់នៅក្នុងស្រុកនោះ។ កណ្ឌគម្ពីរនេះ គឺជាកម្មសិទ្ធិរបស់ កណ្ឌគម្ពីរនិក្ខមនំដែលបង្ហាញពីប្រវត្តិនៃការសង្គ្រោះ ត្រូវបានធ្វើតាមម្តងទៀតក្នុង កិច្ចការពាររបស់ព្រះ។ នៅក្នុងការសង្កត់សង្កិនរបស់អេស៊ីព្ទអស់រយៈពេល ៤៣០ ឆ្នាំ ព្រះបានដាំពូជនៃសេចក្តីសង្គ្រោះសម្រាប់រាស្រ្តទ្រង់។ ទីបំផុតព្រះទ្រង់បានឲទឹកដីសន្យាដែលជាប្រទេសកាណានដល់ពួកគេ។ នៅស្រុកបាប៊ីឡូន របៀបដែលព្រះធ្វើការក្នុងពួកគេ បង្ហាញថាព្រះទ្រង់ជាស្តេច ដែលសុចរិត មេត្តាករុណា នឹងស្មោះត្រង់។ យើងធ្វើការរៀបចំ តាមលំដាប់លំដោយនៃបទគម្ពីរ ហើយពិនិត្យមើលធាតុនានាក្នុងការប្រមើលអនាគតនៃការស្តារឡើងវិញនូវរូបផ្លុះរបស់ព្រះ។

## ១. ស្តេចដែលសោយរាជ្យលើគ្រប់ទាំងសាសន៍ (នាងអេសធើរ ១:១-២២)

វត្ថុបំណងនៃកណ្ឌគម្ពីរអេសធើរ គឺដើម្បីបង្ហាញថា ព្រះទ្រង់ជាស្តេចលើទឹកដីសាសន៍ដទៃ ហើយអ៊ីស្រាអែលគឺជាប្រជារាស្រ្តរបស់ទ្រង់។ តើបទគម្ពីរនេះបង្ហាញអ្វីខ្លះដល់យើង? ទី១ ការតាំងនគរឡើង នឹងត្រូវបន្តគ្រប់ទាំងសាសន៍ លើកលែងតែសាសន៍អ៊ីស្រាអែល។ លោកីយដែលដំណឹងល្អបានផ្សព្វផ្សាយទៅ គឺបានគ្រប់គ្រងដោយសារ ការសោយរាជ្យរបស់ព្រះគ្រីស្ទ។ នគររបស់ស្តេចអ័ហាស៊ូរុស សោយរាជ្យ គឺបង្ហាញពីការសោយរាជ្យរបស់ព្រះគ្រីស្ទ ដោយប្រយោល។ ការតាំងនគរនេះគឺបង្ហាញពីការសោយរាជ្យរបស់ព្រះគ្រីស្ទ ដែលទ្រង់គឺជាស្តេចសាសន៍យូដា ជាស្តេចលើអស់ទាំងស្តេច ហើយជាអម្ចាស់លើអស់ទាំងអម្ចាស់ ដែលគ្មានអ្នកណាម្នាក់អាចបំផ្លាញបានឡើយ។ ទី២ ភាពក្រអឺតក្រទមរបស់ ព្រះនាងវ៉ាសធី ហើយនឹងសេចក្តីកំហឹង របស់ស្តេចអ័ហាស៊ូរុស បង្ហាញពីការបាត់បង់ឱកាសល្អ។ ក្នុង

ចំណោមពួកគេ ព្រះអម្ចាស់បង្កើតបំណងរបស់ទ្រង់ ពីព្រោះទ្រង់គឺជាព្រះនៃប្រាជ្ញា។ ការប្រព្រឹត្តខុសនឹងត្រូវកាត់ទោស។ យើងរាល់គ្នាដែលបានហៅដោយព្រះ ហើយយើងរាល់គ្នាគឺស្តេចនៅក្នុងព្រះគ្រីស្ទយេស៊ូវ យើងអាចបង្ហាញពីការសោយរាជ្យរបស់ទ្រង់ ទៅកាន់លោកីយគ្រប់ពេលវេលានឹងគ្រប់ទីកន្លែង។

## ២. ព្រះហស្តនៃការការពារ (នាងអេសធើរ ២:១-១៨)

កណ្ឌគម្ពីរអេសធើរ មិនឃើញមានពាក្យ ព្រះឬក៏យេហូវ៉ាច្រើនទេ តែព្រះហស្តដ៏មើលមិនឃើញ នៃការការពាររបស់ទ្រង់បានធ្វើការ។ ទី១ ព្រឹត្តិការណ៍ដែលបាន កើតឡើងទីកន្លែងនោះ គឺជាការគ្រប់គ្រង នៃព្រះហស្តរបស់ព្រះ។ ពិធីជប់លៀងដល់ពួកជន ទាំងធំទាំងតូច នឹងរឿងដែលអគ្គមហេសី ត្រូវបានដកតំណែង គឺជាស្នាព្រះហស្តរបស់ព្រះ។ ព្រះពេញដោយព្រះប្រាជ្ញាញាណ។ ទោះបីជាយើង ជួបភាពមិនសមបំណងក៏ដោយ ក៏ព្រះហស្តដ៏អាថ៌កំបាំងរបស់ទ្រង់ តែងតែរៀបចំសម្រាប់យើង(សាស្តា ៧:១៤)។ ទី២ ព្រះហស្តរបស់ទ្រង់មានអំណាចអស្ចារ្យ ជាការអស្ចារ្យទៅទៀត។ ពួកមនុស្សដែលស្ថិតក្នុង ព្រឹត្តិការដែលកើតឡើងនោះ អាចនឹងទទួលបានការក្សាន្តចិត្តចេញមកពីព្រះ។ ពេលដែលយើង ខិតជិតព្រះហើយតោងព្រះហស្តរបស់ទ្រង់ដោយជំនឿ

យើងនឹងឃើញការអស្ចារ្យ ដែលយើងមិនធ្លាប់ឃើញពីមុនមក(យេរេមា ៣៣:៣)។

## ៣. សេចក្តីជំនឿរបស់ម៉ាដេកាយ (អេសធើរ ២: ១៦-៣: ៦)

តាមរយៈនាងអេសធើរ ភាពជាស្តេចរបស់ព្រះត្រូវបានបង្ហាញឲយើញ។ តើបទគម្ពីរ និយាយអ្វីខ្លះអំពីជំនឿរបស់គាត់? ទី១ ភាពស្មោះត្រង់ចំពោះព្រះ បង្ហាញឲយើញពីភាពស្មោះត្រង់ចំពោះមនុស្ស។ ភាពស្មោះត្រង់ចំពោះ ស្តេចអ័ហាស៊ូរុសមានន័យថា ជាម្នាក់ដែលស្មោះត្រង់ចំពោះព្រះ។ ជីវិតរបស់អ្នកជឿព្រះគួរតែធ្វើតាមព្រះបន្ទូលរបស់ព្រះ។ ព្រះជាម្ចាស់ធ្វើការតាមរយៈមនុស្ស ដែលអនុវត្តព្រះបន្ទូលរបស់ទ្រង់។ទី២ គាត់មានជំនឿស្មោះត្រង់ ដែលមិនក្រាបថ្វាយបង្គំដល់ហាម៉ាន។ វាចង្អុលបង្ហាញ ពីអាកប្បកិរិយារបស់ម៉ាដេកាយ ដែលមិនបានឱនក្បាលគោរពដល់ហាម៉ាន ហើយបានបង្ហាញជំនឿរបស់យើងចំពោះព្រះ។ គាត់បានឃើញអាកប្បកិរិយាមិនគោរពព្រះ នៅក្នុងហាម៉ានប្រឆាំងនឹងការកោតខ្លាចដល់ព្រះអម្ចាស់។ វាដូចជាជំនឿដានីយ៉ែល (ដានីយ៉ែល ១: ៧)។ ព្រះរបស់យើង បានកំណត់គោលដៅរបស់ទ្រង់ នឹងទតមើល ការដំណើររបស់យើង នៅពេលដែលយើង អំពាវនាវរកទ្រង់ ហើយទ្រង់សណ្តាប់សេចក្តីសំណូមរបស់យើង។

## ៤. ឧបាយកលរបស់អារក្សសាតាំង (អេស ៣: ៧-១៥)

តើចំណុចណាដែលបង្ហាញថា ហាម៉ានជាគំរូរបស់អារក្សសាតាំង? ទី១ គាត់កត់សម្គាល់ឃើញថា ហាម៉ានបានព្យាយាម បំផ្លាញមនុស្សទាំងអស់ ដោយប្រយោជន៍ផ្ទាល់ខ្លួន។ សាសន៍យូដាជារាស្ត្ររបស់ព្រះ នឹងជាពួកជំនុំក្នុងគម្ពីរសញ្ញាចាស់។ ទោះបីជាអារក្ស តែងតែព្យាយាមបំផ្លាញពួកជំនុំ ដោយប្រើប្រាសគ្រប់មធ្យោបាយ នឹងការប្រើអំណាចផ្លូវងងឹតក្តី ក៏មិនបានសម្រេចដែរ។ ទី២ ពីព្រោះ ហាម៉ាន បះបោរប្រឆាំង នឹងជំនឿដែលការកោតខ្លាចដល់ព្រះយេហូវ៉ា។ សាតាំង បានស្គាល់ពីគំនិតរបស់ម៉ាដេកាយ

ជាអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា នឹងចង់សម្លាប់ម៉ាដេកាយ ដើម្បីប្រឆាំងនឹងការស្គាល់ព្រះ។ ទី៣ គាត់ប្រើអំណាចដើម្បីទទួលផលប្រយោជន៍។ ហាម៉ានបានផ្តល់ប្រាក់ឲស្តេចអ័ហាស៊ូរុស ដើម្បីទទួលការអនុញ្ញាត ទៅសម្លាប់សាសន៍យូដាចោលទាំងអស់។គាត់បានរៀបចំផែនការ យុទ្ធសាស្រ្តយ៉ាងល្អិតល្អន់ ដើម្បីសម្លាប់ពួកគេដោយប្រើវិធីខុសច្បាប់។ ដូច្នេះ យើងត្រូវតែប្រយ័ត្ននឹងការវាយប្រហាររបស់សាតាំង។

## ៥. ស្មារតីបេសកកម្ម (អេសធើរ ៤: ១-១៦)

ក្នុងកណ្ឌគម្ពីរអេសធើរ បង្ហាញថាមានតែព្រះទេដែលជាស្តេចលើសាសន៍ដទៃ។ កំហឹងរបស់ស្តេចអ័ហាស៊ូរុស បានដកតំណែងរបស់ព្រះនាងវ៉ាសធី ហើយបានជំនួសមកវិញនូវនាងអេសធើរ ជាអ្នកមានសេចក្តីជំនឿកោតខ្លាចដល់ព្រះយេហូវ៉ា ហើយបានដោះស្រាយវិបត្តដល់សាសន៍យូដាដែលមានព្រះជាអ្នកគ្រប់គ្រង លើប្រជារាស្រ្តរបស់ទ្រង់។ ជាពិសេស សេចក្តីជំនឿរបស់ម៉ាដេកាយ(អេសធើរ ៤: ៤) បានបង្ហាញ ពីសតិស្មារតី នឹងភាពស្មោះត្រង់។ ទី១ ម៉ាដេកាយ ដឹងពិតប្រាកដថា ព្រះនឹងសង្គ្រោះរាស្រ្តរបស់ទ្រង់ ចេញពីសេចក្តីវេទនា។ប្រសិនបើព្រះនាងអេសធើរមិនបានជួយក៏ដោយ ក៏ព្រះទ្រង់នឹងប្រើប្រាស់វីធីផ្សេងទៀតដែរ។ មូលហេតុដែលព្រះ ដាក់ស្ថានភាពដ៏អាក្រក់បែបនេះ គឺដើម្បីឲពួកគេពឹងផ្អែកលើព្រះទាំងស្រុង (២កូរិនថូស ១:៩)។ ទី២ គាត់ដឹងពិតប្រាកដ តំណែងជាអគ្គមហេសី បានមកពីព្រះ ដើម្បីសម្រេចបំពេញបំណងរបស់ទ្រង់។ អេសធើរគឺជាអ្នកត្រួតត្រាសម្រាប់បម្រើការងាររបស់ព្រះយ៉ាងត្រឹមត្រូវ។  ការដែលស្វែងរកព្រះ គឺជាព្រះពរលើព្រះពរ។យើងគួរតែថ្វាយខ្លួនដល់ព្រះដើម្បីស្អាងសេចក្តីសុចរិត។

## ៦. ការផ្លាស់ប្តូរនៃសេចក្តីអធិស្ឋាន (អេសធើរ ៥: ១-១៤)

តើសេចក្តីអធិស្ឋានរបស់អេសធើរ នាំមកនូវការផ្លាស់ប្តូរអ្វីខ្លះ? ទី១ គឺនាងផ្ទាល់ត្រូវបានផ្លាស់ប្តូរ។ នាងមានសេចក្តីក្លាហាន ដើម្បីចូលគាល់ស្តេច បន្ទាប់ពីការអធិស្ឋានតម អស់រយៈពេល៣ថ្ងៃ។ ដូចជានៅពេលដែលលោកម៉ូសេប្រទល់មុខនឹងព្រះអម្ចាស់ មុខរបស់គាត់មានសភាពចែងចាំង ដោយសារព្រះវត្តមានរបស់ព្រះ នៅក្នុងព្រលឹងវិញ្ញាណគាត់(និក្ខមនំ ៣៤: ២៩-៣៥)។ ហើយទី២វិញនោះ វាគឺជាការផ្លាស់ប្តូរ របស់ស្តេច។ ស្តេចទ្រង់ក៏ប្រោសដល់ព្រះនាង ហើយហុចព្រះដំបងមាស ដែលកាន់នៅព្រះហស្តទៅឯព្រះនាង ដោយសារសម្រស់នៃព្រលឹងវិញ្ញាណរបស់នាង។ដូចពេលដែលអេសាវបានឃើញ យ៉ាកុបដែលបានអធិស្ឋាន នៅឯព្នីអែល គំនុំសងសឹងដ៏ឃោរឃៅទៅលើ យ៉ាកុបត្រូវបានសាបសូន្យទៅ ហើយយំឱបគ្នា។ ទី៣ ការផ្លាស់ប្តូរនៃស្ថានភាព ត្រូវបានផ្លាស់ប្រែ។ ការសព្វព្រះទ័យដែលស្តេចសន្យាថានឹងប្រទានដល់ព្រះនាង ទោះបើដល់នគរ១ចំហៀងក៏ដោយ វាគឺផ្តោតទៅលើដំណោះស្រាយនៃបញ្ហារបស់ព្រះនាង។ ការអធិស្ឋានធ្វើឱ្យអ្វីៗគ្រប់យ៉ាងផ្លាស់ ប្តូរហើយវាជាកូនសោរ ដើម្បីនាំអំណាច តាមរយៈការអធិស្ឋានក្នុងទីលាក់កំបាំង ត្រូវបានបើកនៅទីប្រចក្សច្បាស់វិញ(ម៉ាថាយ ៦: ៦)។ អ្នកដែលស្វែងរក គួរតែទទួលបានរបស់ល្អបំផុតនោះគឺ ព្រះវិញ្ញាណបរិសុទ្ធជាប្រភពនៃព្រះពរ (លូកា ១១:១៣)។

## ៧. ការអធិស្ឋានដោយសេចក្តីជំនឿ (អេសធើរ ៦: ១-១៣)

តើស្ថានការណ៍អ្វី ដែលការអធិស្ឋានរបស់ម៉ាដេកាយនិងអេសធើរ ធ្វើនៅចំពោះមុខ ឧបាយកលរបស់ហាម៉ានដែលបានព្យាយាមសម្លាប់ ជនជាតិយូដាទាំងអស់ក្នុងមួយថ្ងៃ? ទី១ គាត់ទទួលបានផលនៃការផ្លាសប្រែចិត្តរបស់គេ។ ការអធិស្ឋានដោយជំនឿ ដោះស្រាយបញ្ហាពិបាកបាន នឹងសម្រេចកិច្ចការបាន(យេរេមា ៥:១៦)។ ទី២ បន្ទាប់ពីការអធិស្ឋានពីគ្រប់មជ្ឍដ្ឋានទាំងអស់គឺមានទំនោរទៅរកអេសធើរ។ នៅវេលាយប់នោះឯង ស្ដេចទ្រង់ផ្ទំមិនលក់ទេ ដូច្នេះ ទ្រង់បង្គាប់ឲគេយកសៀវភៅ ដែលកត់អស់ទាំងរឿងទុកសម្រាប់ពង្សាវតាមក នោះឃើញមានសេចក្ដីកត់ទុក ពីគុណសម្បត្តិរបស់ម៉ាដេកាយ។ វាមិនមែនជាការចៃដន្យទេ តែវាជាផែនការរបស់ព្រះដោយសារការអធិស្ឋានរបស់គាត់។

គ្រប់កាទាំងអស់ដែលបានសម្រេចដល់ម៉ាដេកាយ នឹងអេសធើរ គឺដោយសារអំណាចនៃការអធិស្ឋាន។

## ៨. ការស្លាប់ដើម្បីសម្លាប់សេចក្ដីស្លាប់ (អេស ៦: ១៤-៧: ១០)

នៅពេលដែលយើង ធ្វើការសញ្ជឹងគិតនៅក្នុងរឿងរ៉ាវ យើងឃើញពន្លឺនៃដំណឹងល្អនៅក្នុងកណ្ឌគម្ពីរនាងអេសធើរ យើងនឹងនឹកឃើញដល់ការសុគតរបស់ព្រះគ្រីស្ទ។ ទី១ ល្បិចកលរបស់ហាម៉ាន អារក្សបានរៀបគម្រោងការ នឹងសំលាប់មនុស្សទាំងអស់ របស់ព្រះទាំងស្រុង។ (ហេព្រើរ ២: ១៤) ទី២ ទោះបីជាអារក្ស បានធ្វើឲគាត់ធ្លាក់ចូលក្នុង  សេចក្ដីនៃព្រលឹងវិញ្ញាណក៏ដោយ ក៏ព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ទរបស់យើង បានសម្រេចបំពេញសេចក្ដីសង្គ្រោះជាស្រេច។ ទ្រង់មានអំណាចលើសេចក្ដីស្លាប់ គឺ

អារក្ស ដោយទ្រង់សុគត (រ៉ូម៥:៨) នៅពេលដែលយើង មើលទៅកាន់ទ្រង់ ដោយក្តីជំនឿ យើងអាចទទួលបានសេរីភាព នឹងការដំណោះស្រាយរាល់បញ្ហាដូចជា ជំងឺ  អំពើបាប បណ្តាសា នឹងការស្លាប់។ ដូច្នេះយើងអាចរស់នៅក្នុងជីវិតដែលមានការធានាអះអាង ថាបន្តិចទៀតព្រះទ្រង់នឹងកិនអារក្សសាតាំង នៅក្រោមជើងអ្នករាល់គ្នាហើយ (រ៉ូម ១៦:២០)។

## ៩. ច្បាប់ថ្មីត្រូវបានប្រកាស (អេសធើរ ៨: ១-១៧)

ទោះបីជា ហាម៉ានបានស្លាប់ហើយក៏ដោយ តែសំបុត្រដែលហាម៉ានផ្ញើរនៅតែដំណើរការ។ ដូច្នេះអេសធើរ មិនបានបញ្ចប់ត្រឹមការស្លាប់របស់ហាម៉ានឡើយ គឺនាងរកវិធីដើម្បីបំផ្លាញសំបុត្រនោះចោល ហើយទីបំផុតច្បាប់ថ្មីត្រូវបានតាំងឡើង ហើយសាសន៍យូដា បានតម្កើងឡើង។ ព្រះបានដាក់ក្រឹត្យវិន័យក្នុងចិត្តគេ ដោយសារព្រះវិញ្ញាណបរិសុទ្ធ។ ចូរអំពាវនាវដល់អញ នោះអញនឹងឆ្លើយតប ហើយនឹងបង្ហាញឲឯងឃើញការយ៉ាងធំ ហើយមុតមាំ ដែលឯងមិនដឹង (យេរេមា ៣៣:៣)។ ការសុគត ការរស់ឡើងវិញ និងការលើកឡើងរបស់ព្រះគ្រីស្ទយេស៊ូ បានសម្រេចបំពេញ នូវសេចក្តីសង្គ្រោះរបស់យើងទាំងស្រុង។ នៅពេលដែល សាសន៍យូដាត្រូវបានលើកតម្កើង គ្រីស្ទានដែលបានកើតជាថ្មី នឹងត្រូវអង្គុយនៅកន្លែងខ្ពស់បំផុត នាពេលអនាគត ដោយការរួបរួមគ្នាជាមួយព្រះគ្រីស្ទ។

## ១០. ចម្បាំងបរិសុទ្ធ (អេសធើរ ៩: ១-១៩)

បទគម្ពីរបង្ហាញយ៉ាងច្បាស់ថា ខ្មាំងសត្រូវទាំងបីរបស់យើង គឺសាតាំង លោកីយ និងសាច់ឈាម។

ទី១ ដូចការស្លាប់របស់ហាម៉ាន មានន័យថា សាតាំងត្រូវបានបំផ្លាញ ដោយការសុគតរបស់ព្រះគ្រីស្ទ។ ដោយសារតែការពិតនេះ ប៉ុលអាចបង្រៀនថា យើងគួរតែ រស់នៅកណ្ដាលព្រះគ្រីស្ទ និងឈើឆ្កាងរបស់ទ្រង់។(១កូរិនថូស ១:២៣) ទី២ ដូចដែល ព្រះរាជបុត្រា របស់ទ្រង់បានសុគត លោកីយ នឹងសាច់ឈាម ត្រូវបានស្លាប់ នៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ។ ឥឡូវនេះ គ្រីស្ទានត្រូវបានសន្យាថា នឹងទទួលជ័យជំនះលើទាំងជ័យជំនះ និងមកុដលើទាំងមកុដ។ យើងគួរតែប្រកាសថា យើងនឹងទទួលបានមកុដ ពីព្រោះយើងនឹងយកឈ្នះចម្បាំងនេះ ក្នុងនាមព្រះយេស៊ូ។ ពិតប្រាកដណាស់ ព្រះនឹងធ្វើឱ្យយើងរីករាយ នឹងជ័យជំនះ របស់អ្នកដែលជិះសេះស។ដូចគ្នានឹងរឿងនេះដែរ តាមរយៈការ ស្នើរសុំរបស់ម៉ាដេកាយ ខ្មាំងសត្រូវទាំងអស់ត្រូវវិនាស។ ប៉ុន្តែ គ្មាននរណាម្នាក់អាចប៉ះពាល់ ទ្រព្យសម្បត្តិរបស់ពួកគេបានទេ។ ប្រសិនបើ គ្រីស្ទានមិនយកចិត្តទុកដាក់ នឹងជ័យជំនះរបស់គេទេ ពួកគេអាចនឹងដាច់ចេញពីព្រះគ្រីស្ទ ដោយព្រោះភាពលោភលន់ ដូចជា អាន្នាំនាស សាភីរ៉ា អេកាន កេហាស៊ី នឹងបាឡាមជាដើម។ ដូចប៉ូលបានធ្វើអ៊ុំចឹង យើងគួរបម្រើព្រះជាមួយការស្ដាប់បង្គាប់ និងភាពបរិសុទ្ធ។

## ១១. ពីសេចក្ដីស្លាប់ដល់ជីវិត (អេសធើរ ៩: ២០-១០: ៣)

ព្រះបានធ្វើរឿងដ៏អស្ចារ្យ ដោយផ្លាស់ប្ដូរទុក្ខវេទនា ទៅជាសេចក្ដីត្រេកអរ នឹងការទួញសោក ទៅជាការអរសប្បាយ។ តើបទគម្ពីរបង្ហាញពីចរិតលក្ខណៈរបស់ដំណឹងល្អ អ្វីខ្លះដល់យើង? ទី១ Prum នៃសេចក្ដីស្លាប់ត្រូវបានផ្លាស់ប្ដូរទៅជា Prum នៃជីវិត។ ដំណឹងល្អ តែងតែធ្វើការអស្ចារ្យបំផុត។ប្រសិនបើ អ្នករាល់គ្នាណាជឿលើព្រះគ្រីស្ទតែមួយគត់ ទោះស្លាប់ គង់តែ

រស់ឡើងវិញ ពីព្រោះព្រះបានពួកប្តូរគេពីសេចក្តីស្លាប់ មកឯជីវិត និងពីសេចក្តីងងឹត មកឯពន្លឺវិញ(កិច្ចការ ២៦:១៨)។ ទី២ តាមរយៈម៉ាដេកាយ និងអេសធើរកិច្ចការដ៏អស្ចារ្យបានកើតឡើង។ (ភីលីព ៤: ៥-៦) ការតម្កើងឡើង របស់ម៉ាដេកាយ បង្ហាញពីការតម្កើងឡើងរបស់ព្រះគ្រីស្ទ និងការយាងរបស់ទ្រង់។ ដូចដែលម៉ាដេកាយបានគ្រប់គ្រង លើពិភពលោកទាំងមូល ដោយព្រះគុណរបស់ព្រះ នោះគ្រីស្ទានក៏ក្លាយជាអ្នកគ្រប់គ្រង លើពិភពលោកទាំងមូលក្នុងព្រះគ្រីស្ទយេស៊ូវដែរ។ យើងគួរតែរស់នៅក្នុងព្រះគុណ ដ៏បរិបូណ៌ នៅក្នុងលោកីយនេះ ដោយជឿដល់ដំណឹងល្អ។

## សរុបសេចក្តី:

សាសន៍អ៊ីស្រាអែល ត្រូវសាសន៍ដទៃបៀតបៀន ព្រះហស្តរបស់ព្រះអង្គតែងតែការពារ ប្រជារាស្ត្ររបស់ទ្រង់ និងសម្រេចបំពេញ បំណងព្រះទ័យរបស់ព្រះអង្គ ការស្តារឡើងវិញនៃរូបឆ្លុះរបស់ទ្រង់។ មានព្រឹត្តិការណ៍ជាច្រើន ដូចជា៖ការព្រួយបារម្ភ វិបត្តិ ការឈឺចាប់ ការខកចិត្ត ការត្អូញត្អែរ និងភាពតានតឹង បានធ្វើឱ្យពួកគេ ត្រូវបានសំអាតចេញពីភាពកខ្វក់ នៅក្នុងចិត្តរបស់ពួកគេ ដោយព្រះហស្តរបស់ព្រះ។ គឺដូចគ្នានឹង សិប្បករម្នាក់ ដែលបានយកចេញផ្នែកដែលមិនស្អាតក្នុងប្រាក់ នៅក្នុងភ្លើង ហើយរង់ចាំរហូតដល់មុខរបស់គាត់អាចឆ្លុះឃើញ មកលើផ្ទៃប្រាក់សុទ្ធ។ ព្រះទ្រង់ធ្វើការនៅក្នុងយើង ដើម្បីបង្ហាញពី ចរិតលក្ខណៈរបស់ទ្រង់ នៅក្នុងជីវិតរបស់យើង ដោយប្រាជ្ញាដ៏អស្ចារ្យរបស់ទ្រង់។ នៅទីបំផុត ព្រះទ្រង់បើកសម្តែង រូបឆ្លុះរបស់ទ្រង់ សេចក្តីសុចរិត សេចក្តីមេត្តាករុណា និងភាពស្មោះត្រង់របស់ព្រះ

អង្គ ក្នុងយើងរហូតដល់ យើងឈានដល់កម្រិតកំពូល នៃការគ្រប់គ្រងជាស្តេចរបស់ទ្រង់ សម្រាប់សិរីរុងរឿងរបស់ព្រះអង្គ។

**ក. ប្រវត្តនៃសេចក្ដីសង្គ្រោះ អែសរ៉ា**

**ខ. ប្រវត្តនៃសេចក្ដីសង្គ្រោះ នេហេមា**

**១. ការអធិស្ឋានរបស់នេហេមា** (នេហេមា ១:៥ ឱព្រះយេហូវ៉ា ជាព្រះនៃស្ថានសួគ៌ គឺជាព្រះដ៏ធំហើយគួរស្ញែងខ្លាច ដែលរក្សាសេចក្ដីសញ្ញា នឹងសេចក្ដីសប្បុរស ដល់អស់អ្នកដែលស្រលាញ់ដល់ទ្រង់ ហើយកាន់តាមអស់ទាំងក្រឹត្យក្រមរបស់ទ្រង់អើយ)។

**២. ការឆ្លើយតបរបស់ព្រះ** (នេហេមា ២:៦ ឯស្តេចទ្រង់មានព្រះបន្ទូលមកខ្ញុំកំពុងដែលអគ្គមហេសីគង់នៅក្បែរទ្រង់ថា តើអ្នកចង់ទៅជាយូរប៉ុន្មាន កាលណានឹងត្រឡប់មកវិញ ដូច្នេះ ស្តេចទ្រង់សព្វព្រះទ័យនឹងចាត់ឲ្យខ្ញុំទៅ ហើយខ្ញុំក៏កំណត់ពេលថ្វាយទ្រង់ជ្រាប)។

**៣. ភាពជាអ្នកដឹកនាំរបស់នេហេមា** (នេហេមា ២:២០ខ្ញុំក៏ឆ្លើយទៅគេថាព្រះនៃស្ថានសួគ៌ទ្រង់នឹងជួយចំរើនដល់យើងរាល់គ្នា ហេតុនោះ យើងរាល់គ្នាជាពួកបំរើទ្រង់ និងលើកគ្នាឡើងធ្វើ តែឯអ្នករាល់គ្នាវិញ គ្មានចំណែក គ្មានច្បាប់ ឬទីនឹករឭកនៅក្រុងយេរូសាឡិមឡើយ)។

**៤. ការកសាងសេចក្តីជំនឿឡើងវិញ** (នេហេមា៣: ២៨ ឯខាងលើទ្វារសេះ នោះពួកសង្ឃបានជួសជុលទល់មុខនឹងផ្ទះគេរៀងខ្លួន)។

**៥. វិធីដើម្បីយកឈ្នះការល្បួង** (នេហេមា ៤:៩ ហើយដោយព្រោះគេ បានជាយើងខ្ញុំអធិស្ឋាន ដល់ព្រះនៃយើងរាល់គ្នា ហើយតាំងពួកចាំយាម ឲ្យរវាំងទាំងយប់ទាំងថ្ងៃ)។

**៦. កិច្ចការរបស់សេចក្តីជំនឿ** (នេហេមា ៤:២០ ដូច្នេះ នៅកន្លែងណាដែលអ្នករាល់គ្នាឮសូរត្រែ នោះត្រូវឲ្យអ្នករាល់គ្នាមូលមកឯយើងនៅទីនោះ ព្រះនៃយើងរាល់គ្នា ទ្រង់នឹងតស៊ូជំនួសយើង)។

**៧. ភាពជាអ្នកដឹកនាំនៃការបម្រើ** (នេហេមា ៥:១៩ ឱព្រះនៃទូលបង្គំអើយ សូមទ្រង់នឹករឭក ដោយចំរើនព្រះគុណដល់ទូលបង្គំផង ដោយព្រោះគ្រប់ទាំងសេចក្តី ដែលទូលបង្គំបានអនុគ្រោះដល់បណ្តាជននេះ)។

**៨. នៅពេលដែលយើងជួបនឹងអ្នកមិនជឿ** (នេហេមា ៦:៩ ពួកអ្នកទាំងនោះចង់តែគំរាម ឲ្យយើងភ័យខ្លាច ដោយគិតថា យើងនឹងថយកំឡាំងដៃ ឲ្យសំរេចការមិនបាន ឥឡូវនេះឱព្រះអង្គអើយ សូមចំរើនកំឡាំងដៃទូលបង្គំវិញ)។

**៩. អំណាចដែលកិច្ចការរបស់ព្រះបាននាំមក** (នេហេមា ៧: ២ នោះខ្ញុំបានប្រគល់អំណាចត្រួតត្រាក្រុងយេរូសាឡិម ដល់ហាណានី ជាបងប្អូនខ្ញុំ និងហាណានា ជាមេបន្ទាយ ដ្បិតគាត់ជាមនុស្សស្មោះត្រង់ ក៏កោតខ្លាចដល់ព្រះលើសជាងមនុស្សជាច្រើន)។

**១០. ពួកជំនុំនៅទីរហោស្ថានបានវិលត្រឡប់មកវិញ** (នេហេមា ៧: ៥ គ្រានោះ ព្រះនៃខ្ញុំទ្រង់បណ្តាលចិត្តខ្ញុំ ឲ្យប្រមូលពួកអ្នកធំ ពួកមេ និងពួកជន ដើម្បីនឹងរាប់គេតាមពង្សាវតារ ខ្ញុំក៏រកឃើញបញ្ជីពង្សាវតារនៃពួកអ្នក ដែលឡើងមកជាន់មុន ហើយខ្ញុំឃើញមានសេចក្តីកត់ទុកក្នុងបញ្ជីនោះថា)។

**១១. ការចាប់ផ្តើមនៃការរួបរួមឡើងវិញ** (នេហេមា ៨:៨ ពួកអ្នកទាំងនោះបានអានមើល ក្នុងគម្ពីរក្រឹត្យវិន័យរបស់ព្រះ ព្រមទាំងស្រាយន័យសេចក្តីឲ្យគេបានយល់បទដែលអានមើលនោះ)។

**១២. ភស្តុតាងនៃការរួបរួមឡើងវិញ** (នេហេមា ៨:១២ ដូច្នេះ ពួកជនក៏នាំគ្នាទៅបរិភោគភោជន៍ ព្រមទាំងជូនជំនូនដល់គេ ហើយតាំងចិត្តអរសប្បាយឡើងជាខ្លាំង ដោយព្រោះបានយល់ន័យសេចក្តីទាំងប៉ុន្មាន ដែលបានថ្លែងប្រាប់ដល់ខ្លួន)។

**១៣. ការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ** (នេហេមា ៩:១ ដុះដល់ថ្ងៃ២៤ ក្នុងខែនោះឯង ពួកកូនចៅអ៊ីស្រាអែល គេបានមូលគ្នាកាន់ត្រណម ដោយស្លៀកពាក់សំពត់ធ្មៃ ហើយព្រលាំងដីនៅខ្លួន)។

**១៤. ព្រះដ៏ស្មោះត្រង់** (នេហេមា ៩: ២០ ទ្រង់បានប្រទានព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់ មកបង្ហាត់បង្រៀនគេ ទ្រង់មិនដែលបង្អត់នំម៉ាន៉ាចំពោះគេទេ ហើយបានប្រទានទឹក ឲ្យគេផឹកផង។ ២១ គឺទ្រង់បានចិញ្ចឹមគេ នៅទីរហោស្ថាន អស់៤០ឆ្នាំ គេឥតមានខ្វះខាតអ្វីឡើយ សំលៀកបំពាក់របស់គេក៏មិនដែលសឹក ហើយជើងគេមិនពុរពងដែរ)។

**១៥. ការស្ដារឡើងវិញនៃការតាំងសញ្ញា** (នេហេមា ១០: ៣៦ព្រមទាំងកូនច្បងរបស់ខ្លួនយើង និងរបស់សត្វយើងផង ដូចជាបានកត់ទុកក្នុងក្រឹត្យវិន័យហើយ និងកូនច្បងក្នុងហ្វូងគោ ហ្វូងចៀមរបស់យើង មកឯព្រះវិហាររបស់ព្រះនៃយើង ឲ្យដល់ពួកសង្ឃដែលធ្វើការងារក្នុងព្រះវិហាររបស់ព្រះនៃយើង)។

**១៦. ទំនួលខុសត្រូវនៃការតាំងទីលំនៅ** (នេហេមា ១១:២ ពួកបណ្ដាជនក៏ឲ្យពរដល់មនុស្សទាំងប៉ុន្មានដែលប្រគល់ខ្លួន ឲ្យមកនៅក្រុងយេរូសាឡិមដោយស្ម័គ្រពីចិត្ត)។

**១៧. ការទទួលយកតង្វាយ** (នេហេមា ១២:៤៧ ហើយនៅគ្រាសូរ៉ូបាបិល និងនេហេមា នោះពួកអ៊ីស្រាអែលទាំងអស់គ្នាក៏ថ្វាយចំណែកសំរាប់ពួកចំរៀង និងពួកឆ្មាំទ្វារ តាមដែលត្រូវការរាល់ៗថ្ងៃ គេក៏លែទុក១ចំណែកឲ្យពួកលេវី ហើយពួកលេវីក៏លែទុក១ចំណែក ឲ្យពួកកូនចៅអើរ៉ុន)។

**១៨. មេដឹកនាំត្រូវស្អាងភាពបរិសុទ្ធ** (នេហេមា ១៣:១១ នៅថ្ងៃនោះឯង គេបានអានមើលក្នុងគម្ពីរលោកម៉ូសេ នៅចំពោះបណ្ដាជន ហើយគេប្រទះឃើញសេចក្ដីដែលចែងទុកមកថា ពួកសាសន៍អាំម៉ូន និងពួកសាសន៍ម៉ូអាប់មិនត្រូវចូលទៅក្នុងពួកជំនុំនៃព្រះឡើយ)។

**១៩. កំណែទម្រង់ដែលពិត** (នេហេមា ១៣:៣១ ហើយសំរាប់ដង្វាយឧសនៅវេលាកំណត់ និងសំរាប់ផលផ្លែដំបូងដែរ ឱព្រះនៃទូលបង្គំអើយ សូមទ្រង់

នឹកចាំពីទូលបង្គំ ដើម្បីនឹងប្រោសឲ្យទូលបង្គំបានប្រកបដោយសេចក្តីល្អផង)។

**គ. ប្រវត្តនៃសេចក្តីសង្គ្រោះ អេសធើរ**

**១. ស្តេចដែលសោយរាជ្យលើគ្រប់ទាំងសាសន៍** (នាងអេសធើរ ១:១ រីឯនៅគ្រាអ័ហាស៊ូរុស ជាស្តេចដែលសោយរាជ្យលើ១២៧ខេត្ត ចាប់តាំងពីស្រុកក្លិង្គ រហូតដល់អេធីយ៉ូពី)។

**២. ព្រះហស្តនៃការការពារ** (នាងអេសធើរ ២:១៨ រួចស្តេចទ្រង់ជប់លៀងជាយ៉ាងធំ ដល់អស់ទាំងពួកអ្នកជាប្រធាន និងពួកជំនិតទ្រង់ទាំងអស់ គឺជាការជប់លៀងរបស់អេសធើរ ទ្រង់ក៏បោស ឲ្យមនុស្សនៅគ្រប់ខេត្តបានឈប់សំរាក ហើយទ្រង់ដាក់ទាន តាមសណ្ឋានស្តេច)។

**៣. សេចក្តីជំនឿរបស់ម៉ាដេកាយ** (អេសធើរ ៣:៥ កាលហាម៉ានឃើញថា ម៉ាដេកាយមិនឱនគោរពដល់ខ្លួនទេ នោះលោកមានចិត្តពេញដោយសេចក្តីក្រោធ)។

**៤. ស្មារតីបេសកកម្ម** (អេសធើរ ៤:១៤ ដ្បិតបើព្រះនាងនឹងស្ងៀមនៅក្នុងវេលានោះ នោះនឹងកើតមានសេចក្តីសង្គ្រោះ និងសេចក្តីប្រោសឲ្យរួច ដល់ពួកយូដាពីកន្លែងផ្សេងទៀត តែព្រះនាង និងញាតិវង្សរបស់បិតានៃព្រះនាងនឹងត្រូវវិនាសវិញ ហើយប្រហែលជាព្រះនាង បានតាំងឡើងក្នុងរាជ្យ សំរាប់ពេលនេះឯងទេដឹង)។

**៥. សេចក្តីសម្រេចចុងក្រោយ** (អេសធើរ ៤:១៦ សូមទៅប្រមូលពួកសាសន៍យូដា ដែលនៅក្រុងស៊ូសានឲប្រជុំគ្នាតមអត់ឲខ្ញុំ កុំឲបរិភោគអ្វីទាំងយប់ទាំងថ្ងៃអស់រវាង៣ថ្ងៃ ឯខ្ញុំ នឹងពួកស្រីបម្រើរបស់ខ្ញុំ ក៏នឹងតមដូច្នោះដែរ យ៉ាងនោះខ្ញុំនឹងចូលទៅគាល់ស្តេច ដែលជាការខុសច្បាប់ហើយបើខ្ញុំត្រូវស្លាប់ ក៏ស្លាប់ទៅចុះ)។

**៦. ការផ្លាស់ប្តូរដោយសារសេចក្តីអធិស្ឋាន** (អេសធើរ ៥: ១៣ ប៉ុន្តែដែលអញនៅឃើញម៉ាដេកាយ ជាសាសន៍យូដានោះ អង្គុយនៅមាត់ទ្វារព្រះរាជវាំងដរាបណានោះសគុណទាំងប៉ុន្មាននេះមិនជាអ្វីដល់អញទេ)។

**៧. ការអធិស្ឋានដោយសេចក្តីជំនឿ** (អេសធើរ ៦:១១ហាម៉ានក៏យកព្រះពស្ត្រាភរណ៍ និងសេះនោះមក រួចបំពាក់ឲ្យម៉ាដេកាយ ហើយបញ្ជិះគាត់បណ្តើរនាំទៅតាមផ្លូវទីក្រុង ដោយស្រែកប្រកាសនៅមុខគាត់ថា អ្នកដែលស្តេចទ្រង់សព្វព្រះទ័យចង់លើកមុខ នោះបានដូច្នេះហើយ)។

**៨. ការស្លាប់ដើម្បីសម្លាប់សេចក្តីស្លាប់** (អេស ៧:១០ គេក៏ចងកហាម៉ានព្យួរនៅឈើ ដែលលោកបានដំឡើងសំរាប់ចងព្យួរម៉ាដេកាយនោះទៅ ដូច្នេះសេចក្តីក្រោធរបស់ស្តេចក៏ស្ងប់បង់)។

**៩. ច្បាប់ថ្មីត្រូវបានប្រកាស** (អេសធើរ ៨:១៥ ឯម៉ាដេកាយលោកចេញពីចំពោះស្តេចទៅ ទាំងស្លៀកពាក់ប្រដាប់របស់ក្រមហ្លួងពណ៌ខៀវ ហើយសមានពាក់មកុដមាសយ៉ាងធំ និងអាវវែង សំពត់ខ្លូតទេសពណ៌ស្វាយផង នោះពួកអ្នកក្រុងស៊ូសានក៏ស្រែកឡើង ដោយអំណរ)។

**១០. ចម្បាំងបរិសុទ្ធ** (អេសធើរ ៩:១៩ គឺដោយហេតុនោះបានជាពួកសាសន៍យូដា ដែលនៅអស់ទាំងទីក្រុងឥតកំផែងនៅស្រុកក្រៅ គេកាន់ថ្ងៃ១៤ខែផល្គុន ជាថ្ងៃសំរាប់រីករាយសាទរ ហើយជប់លៀង ជាថ្ងៃសប្បាយ ហើយជាពេលជូនជំនូនទៅវិញទៅមក)។

**១១. ពីសេចក្តីស្លាប់ដល់ជីវិត** (អេសធើរ៩:២២ ទុកជាថ្ងៃដែលពួកសាសន៍យូដាបានសេចក្តីសាន្តត្រាណ ពីពួកខ្មាំងសត្រូវរបស់គេនឹងជាខែ ដែលសេចក្តីទុក្ខព្រួយរបស់គេបានត្រឡប់ទៅជាសេចក្តីរីករាយសាទរ ហើយសេចក្តីសោកសៅបានទៅជាថ្ងៃសប្បាយវិញ ប្រយោជន៍ឲ្យគេបានតាំងថ្ងៃទាំង២នោះទុកជាថ្ងៃសំរាប់ជប់លៀង ហើយមានសេចក្តីរីករាយសាទរ ព្រមទាំងជូនជំនូនទៅវិញទៅមក ហើយដាក់ទានដល់មនុស្សទាល់ក្រផង)។